# អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី

ក្រុមហ៊ុនមូលបត្រដែលលោកអ្នកជឿទុកចិត្ត



# របាយការណ៍ប្រចាំឆ្នាំ ២០១៨

របាយការណ៍នេះរៀបចំ និងចេញផ្សាយដោយ ក្រុមហ៊ុនអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ។
សម្រាប់ព័ត៌មានបន្ថែម និង ចម្ងល់ផ្សេងៗ សូមទាក់ទងមក ៖


ការិយាល័យកណ្ដាល ៖ ជាន់ទី៥ អគារអេស៊ីលីដា #៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ (០) ២៣ ៩៩៩ ៩៦៦/ ៩៩៩ ៩៧៧/ ៧២៣ ៣៨៨
អ៊ីមែល ៖ info@acledasecurities.com.kh
វេបសាយ ៖ www.acledasecurities.com.kh

## ទស្សនៈ

អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ជាក្រុមហ៊ុនមូលបត្រឈានមុខគេក្នុងប្រទេសកម្ពុជាផ្តល់នូវសេវាល្អបំផុតលើវិស័យមូលបត្រ ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍។

## បេសកកម្ម

បេសកកម្ម របស់ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី គឺផ្តល់ជូនអតិថិជន អ្នកវិនិយោគ និងសាធារណជននូវជម្រើសវិនិយោគដ៏សំបូរបែបលើមូលបត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅនិងប្រភពចំណូលឱ្យប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើតនូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិតព្រមទាំងសហគមន៍ទាំងអស់។

យើងប្រកាន់ខ្ជាប់ជានិច្ចនូវ គោលការណ៍សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថានប្រកបដោយកម្រិតខ្ពស់បំផុត។



# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| | ៣១/១២/២០១៨ បានធ្វើសវនកម្មរួច | | ៣១/១២/២០១៧ បានធ្វើសវនកម្មរួច | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| ក.ទ្រព្យសកម្មសរុប | ២,២៧២,៨០៣ | ៩,១៣២,១២២ | ២,៣០០,១១៦ | ៩,២៨៥,៥៦៨ |
| ខ.បំណុលសរុប | ១២២,០៣៦ | ៤៩០,៣៤០ | ៨៩,២៤៥ | ៣៦០,២៨២ |
| គ.មូលធនសរុប | ២,១៥០,៧៦៧ | ៨,៦៤១,៧៨២ | ២,២១០,៨៧១ | ៨,៩២៥,២៨៦ |
| **លទ្ធផលហិរញ្ញវត្ថុ** | | | | |
| ក.ចំណូលសរុប | ២១៣,៨១៩ | ៨៦៤,៨៩៨ | ៣០៩,២៦៤ | ១,២៥០,៩៧៣ |
| ខ.ចំណេញមុនបង់ពន្ធប្រាក់ចំណេញ | (៤៦,៥៥៧) | (១៨៨,៣២៣) | ៧៨,៩១៨ | ៣១៧,២០០ |
| គ.ចំណេញសុទ្ធក្រោយបង់ពន្ធ | (៤០,២១៧) | (១៦២,៦៧៨) | ៦២,៨៤២ | ២៥៤,១៩៥ |



សកម្មភាពជួបជាមួយមន្ត្រីគណៈកម្មការមូលបត្រកម្ពុជា

# លទ្ធផលសម្រេចបាន












# មាតិកា


ទិន្នន័យហិរញ្ញវត្ថុសង្ខេប ..... ២

លទ្ធផលសម្រេចបាន ..... ៣

របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល ..... ៥

របាយការណ៍អគ្គនាយក ..... ៨

អង្គការលេខ ..... ១១

អភិបាលកិច្ចសាជីវកម្ម ..... ១២

ភាគទុនិក ..... ១២

ក្រុមប្រឹក្សាភិបាល ..... ១២

គណៈកម្មាធិការប្រតិបត្តិ ..... ១៤

គណៈគ្រប់គ្រង ..... ១៥

ក្រមសីលធម ..... ១៦

និរន្តរភាពបរិស្ថាន និងសង្គម ..... ១៦

របាយការណ៍ក្រុមប្រឹក្សាភិបាល ..... ១៨

របាយការណ៍របស់សវនករឯករាជ្យ ..... ២២

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ..... ២៦

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ ..... ២៧

របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ..... ២៨

របាយការណ៍លំហូរសាច់ប្រាក់ ..... ២៩

កំណត់សម្គាល់លើរបាយការណ៍ ..... ៣០

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



**លោកស្រី ម៉ារ អមរា**

ប្រធានក្រុមប្រឹក្សាភិបាល

"ជំនួសមុខឱ្យក្រុមប្រឹក្សាភិបាលនៃអេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ដែលជាក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ នាងខ្ញុំមានសេចក្ដីសោមនស្សរីករាយ ក្នុងការបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំ ២០១៨ ជូនដល់ភាគហ៊ុនិក និងអ្នកពាក់ព័ន្ធផ្សេងៗទៀតរបស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ។"

## សេដ្ឋកិច្ចកម្ពុជា

ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករណ៍ថា កំណើនសេដ្ឋកិច្ចនឹងកើនឡើង ៧% សម្រាប់ឆ្នាំ២០១៩ ។ កំណើននេះបន្តរីកចម្រើនក្នុងល្បឿនមួយដ៏រឹងមាំ ដោយជំរុញពិពិធកម្មនាំចេញ សំណង់រឹងមាំ សកម្មភាពទេសចរណ៍ លក្ខខណ្ឌផ្សេងៗល្អប្រសើរ និងការគាំទ្រលើគោលនយោបាយសារពើពន្ធ ។

## វិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា

ដោយសារតែព្រះរាជាណាចក្រកម្ពុជាមានសន្តិភាព ស្ថិរភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ទើបធ្វើឱ្យមានក្រុមហ៊ុនធានាទិញមូលបត្រ ចំនួន ៦ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ចំនួន ១ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រចំនួន ៣ និងក្រុមហ៊ុនបោះផ្សាយមូលបត្រចំនួន ៦ បានចុះបញ្ជីនៅគណៈកម្មការមូលបត្រកម្ពុជា ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវបានរំពឹងថា នឹងនៅតែបន្តកើនឡើងផងដែរនៅក្នុងឆ្នាំ២០១៩ ។

យើងខ្ញុំសូមស្វាគមន៍ចំពោះបទប្បញ្ញត្តិថ្មីៗដែលបានចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលផ្ដោតលើការឆ្លើយតបទៅនឹងតម្រូវការកាត់បន្ថយហានិភ័យ ការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ ហើយជាពិសេស ដើម្បីពង្រឹងការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ ក្នុងចំណោមយន្តការជាច្រើនផ្សេងទៀត ដែលមានគោលដៅល្អបំផុតដើម្បីធានាកំណើនប្រកបដោយនិរន្តរភាពនៅក្នុងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

## អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី

ក្នុងឆ្នាំ២០១៨ នេះ ក្រុមហ៊ុន អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី បានបន្តអនុវត្តគោលដៅចម្បង ដែលបានចែងនៅក្នុងយុទ្ធសាស្ត្ររយៈ

ពេល ៥ឆ្នាំ (២០១៨ ដល់ ២០២២) របស់ខ្លួន ដើម្បីក្លាយជាក្រុមហ៊ុនឈ្នួញជើងសាមូលបត្រឈានមុខជាមួយនឹងការប្រកួតប្រជែងនៅក្នុងទីផ្សារ។ការផ្តល់តម្លាភាព និងទំនុកចិត្ត ទៅដល់អ្នកដែលពាក់ព័ន្ធ គឺជាចំណូលរយៈពេលវែង ដោយយើងនៅតែបន្តគាំទ្រដល់របៀបវារៈកំណើនសេដ្ឋកិច្ច និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ចតុកោណរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី នៅតែបន្តពង្រឹងគំរូអាជីវកម្មរបស់ខ្លួន និងសម្រួលដល់ការផ្តល់សេវាកម្មជួញដូរមូលបត្រដល់អតិថិជន នៅលើផ្សារមូលបត្រកម្ពុជា ដើម្បីស្វែងរកប្រាក់ចំណូលប្រកបដោយនិរន្តរភាពយូរអង្វែង និងផ្តល់ផលប្រយោជន៍ដល់ភាគហ៊ុនិករបស់ខ្លួន ។

ក្នុងឆ្នាំនេះ និងឆ្នាំក្រោយតទៅមុខទៀត អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី នឹងនៅតែបន្តបង្កើនសេវាជួញដូរមូលបត្រដ៏ល្អប្រសើរ និងភាពងាយស្រួលដល់អតិថិជន ។

## សមាសភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានអភិបាលសរុបចំនួន ៣រូប ដែលក្នុងនោះមាន ២រូប ជាអភិបាលមិនប្រតិបត្តិ និង ១រូបទៀត ជាអភិបាលប្រតិបត្តិ។ ក្នុងឆ្នាំ២០១៨ មិនមានការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាលទេ ។

## អភិបាលកិច្ច

ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រង មានភារកិច្ចទទួលខុសត្រូវធានាឱ្យបាននូវរាល់ប្រតិបត្តិការរបស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ទាំងអស់ត្រូវបាន និងកំពុងអនុវត្តស្របតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ក៏ដូចជាប្រតិបត្តិការដែលនឹងកើតឡើងនាពេលខាងមុខផងដែរ ។

ដោយយោងលើតួនាទី និងភារកិច្ច ក្រុមប្រឹក្សាភិបាល ត្រូវជួបប្រជុំ ៤ដង យ៉ាងទៀងទាត់ យ៉ាងតិចក្នុងមួយឆ្នាំ ដោយពិនិត្យមើលលើការអនុវត្តរបស់គណៈគ្រប់គ្រង និងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើប្រតិបត្តិការរបស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ។

## ទស្សនវិស័យ ឆ្នាំ២០១៩

យោងតាមការព្យាករណ៍របស់ធនាគារពិភពលោក ស្តីពីកំណើនសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា គឺនៅរក្សាកំណើនស្ថិរភាពប្រហែល ៧% ក្នុងឆ្នាំ២០១៩ ។ ធនាគារពិភពលោក បានបន្ថែមទៀតថាព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមឡើងលើខ្សែសង្វាក់ផលិតកម្មលើវិស័យកាត់ដេរ អេឡិចត្រូនិក និងគ្រឿងបន្លាស់រថយន្ត ។ ដើម្បីទ្រទ្រង់និន្នាការទាំងនេះ ព្រះរាជាណាចក្រកម្ពុជាត្រូវតែចាប់ផ្តើមកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធកាន់តែស៊ីជម្រៅក្នុងការលើកកម្ពស់បរិយាកាសធុរកិច្ចពិធីកម្មនាំចេញ កាត់បន្ថយថ្លៃដើមនៃការដឹកជញ្ជូនដោយកាត់បន្ថយគម្លាតជំនាញ។

## ការទទួលស្គាល់

ក្នុងនាមក្រុមប្រឹក្សាភិបាល នាងខ្ញុំ សូមថ្លែងអំណរគុណដល់អតិថិជន ភាគហ៊ុនិក អភិបាល គណៈគ្រប់គ្រង និងបុគ្គលិកគ្រប់លំដាប់ថ្នាក់របស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ទាំងអស់ ដែលបានគាំទ្រ និងខិតខំប្រឹងប្រែងអនុវត្តតាមយុទ្ធសាស្ត្ររបស់ខ្លួនធ្វើឱ្យអេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី សម្រេចបានជោគជ័យតាមគោលដៅ និងបំណងរបស់ខ្លួន ។

យើងខ្ញុំក៏សូមសម្តែងនូវការដឹងគុណដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និយ័តករ ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលតែងតែជួយគាំទ្រ និងប្រឹងប្រែងអភិវឌ្ឍឧស្សាហកម្មហិរញ្ញវត្ថុកម្ពុជា ជាពិសេសវិស័យមូលបត្រ ។

យើងខ្ញុំសូមធានាចំពោះអតិថិជនព្រមទាំងភាគហ៊ុនិកទាំងអស់ថា នៅឆ្នាំ២០១៩ នេះ យើងខ្ញុំនឹងបន្តយកចិត្តទុកដាក់ និងបន្តខិតខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការសម្រេចឱ្យបាននូវភាពជោគជ័យ រីកចម្រើន និងមាននិរន្តរភាព ព្រមទាំងផ្តល់នូវ គោលដៅយុទ្ធសាស្រ្តក្នុងការបង្កើនប្រាក់ចំណេញ នាពេលអនាគត ក៏ដូចជាពង្រឹងជំហររបស់អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។



**លោកស្រី ម៉ារ អមរា**

ប្រធានក្រុមប្រឹក្សាភិបាល

អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី

ថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩



សកម្មភាពបំពេញបែបបទស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជន

# របាយការណ៍អគ្គនាយក



**លោក ព្រុំ វិសុទ្ធ**

**អគ្គនាយក**

"ការអភិវឌ្ឍពហុសេវា និងការបង្កើនប្រភពចំណូល ព្រមទាំងប្រសិទ្ធភាពចំណាយ គឺជាគោលដៅចម្បងរបស់អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ដើម្បីបន្តនិរន្តរភាពអាជីវកម្មនៅក្នុងទីផ្សារមូលបត្រវ័យក្មេង ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបានរៀបចំយ៉ាងល្អជាមួយនឹងយុទ្ធសាស្ត្ររួមរបស់អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ដែលជាស្នូលនៃការអភិវឌ្ឍប្រកបដោយចីរភាព និងភាពខ្លាំងរបស់អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ។"

## សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨

### ស្ថានភាពប្រកួតប្រជែង

ទោះបីជាវិស័យមូលបត្រកម្ពុជាទើបតែមានអាយុកាល ៦ឆ្នាំ ក៏ដោយ ក៏វិស័យនេះ នៅតែជាទីចំណាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះគ្រឹះស្ថានសាធារណៈ និងឯកជនរួមមានក្រុមហ៊ុនសូយ័តសាធារណៈ ក្រុមហ៊ុនឯកជន ព្រមទាំងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ដោយសារតែកំណើននៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនៅលើទីផ្សារមូលបត្រកម្ពុជា នៅមានកម្រិតនៅឡើយ ដូច្នេះការប្រកួតប្រជែងក៏នៅមានកម្រិតផងដែរ នៅក្នុងវិស័យនេះ។ ទោះបីយ៉ាងណាក៏ដោយ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី នៅតែមានជំហរដ៏រឹងមាំ និងបន្តនិរន្តរភាពនៃអាជីវកម្ម ព្រមទាំងនាំមុខទីផ្សារក្នុងវិស័យនេះ ។

### ចំណុចសំខាន់ៗនៃប្រតិបត្តិការក្នុងឆ្នាំ២០១៨

- សមតុល្យគណនីជួញដូរនៅ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី សរុបចំនួន ១៣,៧២៥ គណនី បានកើនឡើង ៣៦៧.៩៥% ឬចំនួន ១០,៧៩២ ។ បើប្រៀបធៀបកាលពីឆ្នាំ២០១៧ គណនីជួញដូរនៅ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី មានចំនួន ២,៩៣៣ គណនី ។
- នៅក្នុងឆ្នាំ២០១៨ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី បានចុះកិច្ចសន្យាជាភ្នាក់ងារលក់ជាមួយក្រុមហ៊ុនធានាទិញមូលបត្រសម្រាប់

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុន ផេសចិក (ខេមបូឌា) លីមីតធីត ។
- អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី បន្តកាត់បន្ថយចំណាយ និងត្រួតពិនិត្យហានិភ័យដើម្បីទប់ទល់នឹងចំណូលពីប្រតិបត្តិការ ។
- បានធ្វើអោយប្រសើរឡើងនូវគេហទំព័រ ដើម្បីផ្តល់ព័ត៌មានសម្បូរបែប និងគ្រប់ជ្រុងជ្រោយដល់វិនិយោគិន ស្វែងយល់ វិភាគ និងសម្រេចចិត្តជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រកម្ពុជា ។

## សេវាឈ្មួញជើងសាមូលបត្រ

គណនីជួញដូរនៅអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី មានចំនួន ១៣,៧២៥ បានកើនឡើង ៣៦៧,៩៥% ឬចំនួន ១០,៧៩២ បើប្រៀបធៀបនឹងចំនួនគណនីជួញដូរនៅក្នុងទីផ្សារមូលបត្រកម្ពុជា ស្មើនឹង ៦៦,៨៣% ។ បើប្រៀបធៀបកាលពីឆ្នាំ២០១៧ គណនីជួញដូរនៅអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ីមានចំនួន ២,៩៣៣ ។

សមតុល្យនៃភាគហ៊ុនរបស់វិនិយោគិននៅអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ថយចុះ ១,៣៥% ខណៈដែលសមតុល្យនៃសាច់ប្រាក់របស់វិនិយោគិននៅអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី កើនឡើង ៩៩,៥២% ។ ចំនួនវិនិយោគិនសកម្មដែលមានសមតុល្យភាគហ៊ុន និងសាច់ប្រាក់នៅអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី កើនឡើង ១៥,៧០% ។

បរិមាណជួញដូរមូលបត្ររបស់វិនិយោគិននៅអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី បានថយចុះ ២២,៦៨% និងទំហំជួញដូរមូលបត្រ បានថយចុះ ២០,២៩% ។

## សេវាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

សេវាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ចាប់ផ្តើមពាក់កណ្តាលឆ្នាំ២០១៨ ហើយបានធ្វើជាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ដែលសញ្ញាបណ្ណនេះ បោះផ្សាយដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបញ្ញើសន្សំ ហត្ថាកសិករ លីមីតធីត នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ដែលមានទំហំ ១២០,០០០,០០០,០០០ រៀល សមមូលនឹង ៣០,០០០,០០០ ដុល្លារអាមេរិក រយៈពេល ៣ឆ្នាំ ដែលមានអត្រាការប្រាក់ចំនួន ៨,៥% ក្នុងមួយឆ្នាំ ។

# យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៩

- កំណើនជាមួយនឹងក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងចំណូលពីថ្លៃសេវា ផ្តោតលើការបង្កើតបទពិសោធន៍ដ៏ល្អបំផុតជាមួយវិនិយោគិនដោយធ្វើឱ្យកាន់តែសាមញ្ញ និងមានប្រសិទ្ធភាពព្រមទាំងផ្តល់នូវកំណើនប្រកបដោយចីរភាព។
- ខិតខំយកចិត្តទុកដាក់អភិវឌ្ឍន៍ "វប្បធម៌បម្រើសេវា" របស់យើងឱ្យមានភាពងាយស្រួល និងឆាប់រហ័សដល់វិនិយោគិន និងបង្កើនសេវាកម្មរបស់យើងក្នុងពេលដែលទីផ្សារីកកាន់តែធំ ។

- ផ្តោតលើការពង្រីកគុណភាពសេវាបន្ថែមដើម្បីឱ្យមានចំណូលចម្រុះ ។
- រៀបចំយុទ្ធសាស្ត្រចាប់ដៃគូជាមួយនឹងក្រុមហ៊ុនធានាទិញមូលបត្រ និងក្រុមហ៊ុនបោះផ្សាយនៅក្នុងប្រទេស ដើម្បីអភិវឌ្ឍ និងពង្រីកសេវាកម្មរបស់អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ។
- បង្កើតតួនាទីឈានមុខគេលើសេវាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ដើម្បីពង្រីក ចំណែកទីផ្សារក្នុងទីផ្សារមូលបត្រកម្ពុជា ។
- បង្កើត និងអភិវឌ្ឍពហុសេវាក្នុងទីផ្សារមូលបត្រ ទាំងទីផ្សារដំបូង និងបន្ទាប់ ជូនវិនិយោគិន ព្រមទាំងសហការជាមួយក្រុមហ៊ុនធានាទិញមូលបត្រ ដែលមានសក្តានុពល ដៃគូឯកទេស/ជំនាញ ដើម្បីរួមគ្នាអភិវឌ្ឍផលិតផលសម្រាប់បម្រើជូនដល់វិនិយោគិនដើម្បីទទួលបានប្រាក់ចំណូលខ្ពស់ ។

## បញ្ហាចម្បងក្នុងឆ្នាំ២០១៩

សន្ទុះយឺតនៃចំនួនក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល នៅលើទីផ្សារមូលបត្រកម្ពុជា នាំមកនូវបញ្ហាប្រឈមនានាដល់ក្រុមហ៊ុនមូលបត្រ ។ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី អាចនឹងមានផលប៉ះពាល់លើចំណូលរបស់ខ្លួន ប្រសិនបើពុំមានក្រុមហ៊ុនថ្មីៗបោះផ្សាយមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលបន្ថែម នៅលើទីផ្សារមូលបត្រកម្ពុជានោះទេ ។

ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវិនិយោគិនដ៏វៃឆ្លាត ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិក ព្រមទាំងរាជរដ្ឋាភិបាល គណៈកម្មការមូលបត្រកម្ពុជា និងទីផ្សារមូលបត្រកម្ពុជា ដែលបានគាំទ្រដល់ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ក្នុងឆ្នាំ២០១៨ កន្លងមក ។ សូមជូនពរដល់លោកអ្នក និងក្រុមគ្រួសារ ក្នុងឆ្នាំ២០១៩ ទទួលបាននូវសេចក្តីសុខកាយ សប្បាយចិត្ត ចម្រើនដោយប្រយោជន៍ ជោគជ័យក្នុងនាទីការងារនិងមុខជំនួញ ប្រកបដោយគុណភាព និងប្រសិទ្ធភាពដ៏ឧត្តុង្គឧត្តមកុំបីឃ្លៀងឃ្លាតឡើយ។



**លោក ព្រំ វិសុទ្ធ**
អគ្គនាយក អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
ថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

# ឧបសម្ព័ន្ធលេខ២

## រចនាសម្ព័ន្ធគ្រប់គ្រង អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី

## Organizational Chart of ACLEDA Securities Plc.



# អភិបាលកិច្ចសាជីវកម្ម

អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ទទួលស្គាល់នូវលក្ខណៈដ៏សំខាន់នៃអភិបាលកិច្ចសាជីវកម្ម ដើម្បីគាំទ្រពីស្ថិរភាពនៃការរីកចម្រើន បង្កើនប្រសិទ្ធភាពការងារ និងប្រាក់ចំណេញ បង្កើនតម្លៃរបស់ភាគទុនិក និងជំនឿទុកចិត្តដល់ភាគទុនិក អតិថិជន បុគ្គលិក ព្រមទាំងសាធារណៈជនទូទៅ ។ ក្រុមប្រឹក្សាភិបាលគាំទ្រ និងលើកទឹកចិត្តឲ្យអនុវត្តគោលនយោបាយអភិបាលកិច្ចសាជីវកម្ម រួមទាំងក្រមសីលធម៌ ។

# ភាគទុនិក

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាភាគទុនិករបស់ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ដែលកាន់កាប់ភាគហ៊ុន ១០០% ។ ភាគទុនិកមានសិទ្ធិអនុម័តលើយុទ្ធសាស្ត្រនានា ប៉ុន្តែភាគទុនិកពុំមានសិទ្ធិអំណាចគ្រប់គ្រងផ្ទាល់លើការងារទាំងអស់នេះទេ ទោះបីយ៉ាងណាក៏ដោយភាគទុនិកអាចផ្ទេរការទទួលបន្ទុកទាំងនេះទៅឲ្យក្រុមប្រឹក្សាភិបាល តាមរយៈអនុស្សរណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

# ក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយភាគទុនិកសម្រាប់អាណត្តិ ៣ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឲ្យពួកគេផ្ទាល់ ។ តាមលក្ខន្តិកៈបានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវមានសមាជិកយ៉ាងតិច ៣ (បី) រូប រួមមាន ៖



(ពីឆ្វេងទៅស្តាំ) លោក ព្រំ វិសុទ្ធ, លោកស្រី ម៉ា អមរា, លោកបណ្ឌិត ឡឹង សុភាព



## លោកស្រី ម៉ារ អមរា ប្រធានក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ កើតក្នុងខែកញ្ញា ឆ្នាំ១៩៦៧ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៣ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី លោកស្រីក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកស្រីជាប្រធានគណៈកម្មាធិការ Implementation & Conversion of IFRS (International Financial Reporting Standards), ជាប្រធានគណៈកម្មាធិការស្វ័យប្រវត្តិកម្ម និងការធ្វើទំនើបកម្ម ជាសមាជិកាគណៈកម្មាធិការកំណត់ថ្លៃលើផលិតផល និងសេវាកម្ម និងគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។ លោកស្រីក៏ជាអ្នកដឹកនាំការងារ Basel Team ផងដែរ ។ លោកស្រីគ្រប់គ្រងលើនាយកដ្ឋានហិរញ្ញវត្ថុ ។ លោកស្រីទទួលខុសត្រូវផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ លោកស្រីក៏ជាអនុប្រធានក្រុមប្រឹក្សាភិបាលនៃ អេស៊ីលីដា ហ្វាយណាន់ហ្សលត្រាស់ ។ លោកស្រីបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្មជំនាញហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៦ និងបានបញ្ចប់បរិញ្ញាបត្រពាណិជ្ជសាស្ត្រជំនាញគ្រប់គ្រង ក្នុងឆ្នាំ២០០៣ ។ ក្រៅពីនោះនៅមានវគ្គសិក្សាជាច្រើនទៀត ដូចជា គណនេយ្យគ្រប់គ្រង គណនេយ្យហិរញ្ញវត្ថុ និងសវនកម្ម ជាដើម នៅសាកលវិទ្យាល័យ Regent ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៨ នៅក្នុងប្រទេសកម្ពុជា ។ លោកស្រីត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ក្នុងឆ្នាំ២០១៤ ។



## លោក ព្រំ ចិសុទ្ធ អភិបាល

ជនជាតិខ្មែរ កើតនៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៥ ។ លោកទទួលបានអនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី ។ លោកបានបម្រើការនៅ ធនាគារ អេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៨ ក្នុងមុខតំណែងជាគណនេយ្យករ បន្ទាប់មកជាប្រធានផ្នែកត្រួតពិនិត្យឥណទាន បន្ទាប់មកទៀតជានាយកសាខា ក្រោយមកជាប្រធានក្រុមកិច្ចការច្បាប់និងលេខាធិការក្រុមហ៊ុន ក្រោយមកទៀត ជានាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន និងតំណែងចុងក្រោយជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន ។ ការទទួលខុសផ្សេងៗទៀតក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ លោកជាសមាជិក

ក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងអេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី និងជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ប្រភើធី អិលធីឌី ។ លោកត្រូវបានតែងតាំងជា សមាជិកក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ក្នុងឆ្នាំ២០១០ និងជាអគ្គនាយក អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ។



### បណ្ឌិត ឡឹង សុភាព អភិបាល

ជនជាតិខ្មែរ កើតនៅខែមីនា ឆ្នាំ១៩៦៧ លោកបណ្ឌិតទទួលបានមហាបរិញ្ញា (ថ្នាក់បណ្ឌិត) គ្រប់គ្រងធុរកិច្ចហិរញ្ញវត្ថុនៃសកលវិទ្យាល័យ PRESTON របស់សហរដ្ឋអាមេរិក នៅទីក្រុងភ្នំពេញ នៅឆ្នាំ២០១២។ បណ្ឌិត ឡឹង សុភាព បានចូលបម្រើការងារនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ីតាំងពីឆ្នាំ១៩៩៧។ ក្នុងមុខតំណែងជានាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល លោកបណ្ឌិតទទួលបន្ទុកក្នុងការអភិវឌ្ឍ និងកែលម្អផលិតផល និងសេវាកម្មដែលមានស្រាប់ និងបង្កើតថ្មីរបស់ធនាគារ អេស៊ីលីដា។ បន្ថែមពីនេះទៅទៀត លោកបណ្ឌិតគឺជាប្រធានគណៈកម្មាធិការអេឡិចត្រូនិកដែលទទួលបន្ទុកលើការអភិវឌ្ឍ ប័ណ្ណអេស៊ីលីដា អេស៊ីលីដាអ៊ីនធឺណែត អេស៊ីលីដាយូនីធីទាន់ចិត្ត (ToanChet) និងផលិតផលសេវាកម្មផ្សេងៗទៀតដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) និងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យនៃក្រុមហ៊ុនមេ ។ លោកបណ្ឌិតត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី នៅខែកក្កដា ឆ្នាំ២០១៧។

# គណៈកម្មាធិការប្រតិបត្តិ

អគ្គនាយកត្រូវបានតែងតាំងឡើងដោយ ក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវ និងមានសិទ្ធិពេញលេញ ក្នុងការចាត់ចែងការងារប្រចាំថ្ងៃរបស់ អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី នៅក្នុងរង្វង់គោលការណ៍ និងយុទ្ធសាស្ត្រ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ទោះជាយ៉ាងណា ភាពច្បាស់លាស់នៃសិទ្ធិអំណាច អាចត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល និងការកត់ត្រាទុកជាផ្លូវការនៅក្នុង " Letter of Reserved Matters" ។

អគ្គនាយក ជាអ្នកតែងតាំង និងដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលរួមមាន សមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលលោកយល់ឃើញថាសមស្រប ។ អគ្គនាយក ជាអ្នកកំណត់ពេលវេលាប្រជុំ និងកិច្ចដំណើរការនៃគណៈកម្មាធិការប្រតិបត្តិ ក្រោមការដឹកនាំផ្ទាល់ ប្រកបដោយភាពមធ្យ័តទៅលើ ៖

- យុទ្ធសាស្ត្រផ្ទាល់ ៖ អភិវឌ្ឍគោលការណ៍, កំណត់គោលដៅ, យុទ្ធសាស្ត្រ និងទិសដៅ សម្រាប់ដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត ។
- ការអនុវត្ត ៖ ប្រមូលផ្តុំនូវរាល់ធនធាន ដើម្បីអនុវត្តទៅតាមយុទ្ធសាស្ត្រដែលបានព្រមព្រៀង និងប្រតិបត្តិទៅតាមគោលដៅ ដែលបានកំណត់ ។

- ហានិភ័យ ៖ កំណត់ និងវាយតម្លៃទៅលើហានិភ័យ នៅក្នុងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងចាត់ចែងបញ្ហាដែលកើតឡើង ។
- ការប្រតិបត្តិ ៖ ធានាថាក្រុមហ៊ុនប្រតិបត្តិស្របតាមតម្រូវការ របស់សាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។

# គណៈគ្រប់គ្រង



## លោក ច្រាំ វិសុទ្ធ អគ្គនាយក

ជនជាតិខ្មែរ កើតនៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៥ ។ លោកទទួលបានអនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី ។ លោកបានបម្រើការនៅ ធនាគារ អេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៨ ក្នុងមុខតំណែង ជាគណនេយ្យករ បន្ទាប់មកជាប្រធានផ្នែកត្រួតពិនិត្យឥណទាន បន្ទាប់មកទៀតជានាយកសាខា ក្រោយមកជាប្រធានក្រុមកិច្ចការច្បាប់ និងលេខាធិការក្រុមហ៊ុន ក្រោយមកទៀតជានាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន និងតំណែងចុងក្រោយជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន ។ ការទទួលខុសផ្សេងៗទៀតក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ លោកជាសមាជិកក្រុមប្រឹក្សាភិបាលនៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និង អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ អេស៊ីលីដា ប្រភើធី អិលធីឌី ។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ក្នុងឆ្នាំ២០១០ និងជាអគ្គនាយក អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ។



## លោក ហោ ស៊ីម៉េត នាយកប្រតិបត្តិការ

ជនជាតិខ្មែរ កើតនៅឆ្នាំ១៩៨០ ។ នៅឆ្នាំ២០០៧ លោកបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង នាទីក្រុងភ្នំពេញ ។ លោក បានទទួលបរិញ្ញាបត្រផ្នែកគណនេយ្យ នៅវិទ្យាស្ថានជាតិគ្រប់គ្រង នាទីក្រុងភ្នំពេញ ក្នុងឆ្នាំ២០០៣ ។ បានប្រលងចេញ ពីវិទ្យាល័យព្រះស៊ីសុវត្ថិ នៅឆ្នាំ១៩៩៨ ។ លោកបានចូលរួមសិក្សាវគ្គជំនាញផ្នែកមូលបត្រ នៅព្រះរាជាណាចក្រកម្ពុជា និងនៅសាធារណរដ្ឋកូរ៉េ ។ លោក ហោ ស៊ីម៉េត បានចូលបម្រើការងារ នៅក្នុងធនាគារ អេស៊ីលីដា តាំងពីឆ្នាំ២០០៣ និងបានធ្វើជាប្រធានផ្នែកគណនេយ្យនៅក្នុងនាយកដ្ឋានហិរញ្ញវត្ថុ នៅឆ្នាំ២០០៤ ហើយធ្វើជាប្រធានផ្នែកមូលបត្រ តាំងពីខែមករា ឆ្នាំ២០០៩ ។ លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិការ និងហិរញ្ញវត្ថុ ក្នុងខែមីនា ឆ្នាំ២០១០ និងចាប់តាំងពីខែមីនា ឆ្នាំ២០១៩ លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិការ នៅក្នុង អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ។



### អ្នកស្រី ម៉ៅ ភិរក្ស ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ

កើតនៅក្នុងឆ្នាំ១៩៨១ អ្នកស្រីបានទទួលអនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅរាជធានីភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ។ អ្នកស្រីបានទទួលបរិញ្ញាបត្រគ្រប់គ្រងអាជីវកម្ម ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅរាជធានីភ្នំពេញ ក្នុងខែសីហា ឆ្នាំ២០០៣ ។ អ្នកស្រីបានប្រលងចេញពីវិទ្យាល័យកំពង់ធំ នៅឆ្នាំ១៩៩៨ ។ អ្នកស្រី ម៉ៅ ភិរក្ស បានចូលបម្រើការងារឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងខែមេសា ឆ្នាំ២០០៤ ហើយអ្នកស្រីបានធ្វើជា អនុប្រធានផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស នៃនាយកដ្ឋានធនធានមនុស្ស នៅខែកញ្ញា ឆ្នាំ២០០៧ ហើយត្រូវបានផ្លាស់ប្តូរតួនាទីជាអនុប្រធានផ្នែកវិនិយោគ នៃនាយកដ្ឋានកិច្ចការវិនិយោគ និងមូលបត្រ នៅខែមករា ឆ្នាំ២០០៩ ។ អ្នកស្រីត្រូវបានតែងតាំងជាប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ នៅក្នុងអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី នៅខែមីនា ឆ្នាំ២០១៦ ។

# ក្រមសីលធម៌

កម្មករនិយោជិតគ្រប់រូបរបស់ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ស្ថិតក្រោមការគ្រប់គ្រងមួយ យ៉ាងតឹងរឹងនៃក្រមសីលធម៌ ដែលបានកំណត់ក្នុងអនុសញ្ញារួមការងារ ដោយគ្របដណ្តប់លើបញ្ហាមួយចំនួនដូចជាចរិតលក្ខណៈបុគ្គល ទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជន និងអ្នកគ្រប់គ្រង អាថ៌កំបាំង និងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ និងការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបកអាក្រាតកំហុសឆ្គង ។ ឯកសារទាំងនេះ ត្រូវបានត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ ដោយក្រុមហ៊ុនមេ ដើម្បីធានាថា វានៅតែមានសុពលភាពប្រើប្រាស់ និងទាន់សម័យ ។

# និរន្តរភាពបរិស្ថាន និងសង្គម

### បេសកកម្មស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង ព្យាយាមឲ្យទទួលបាននូវនិរន្តរភាពនៃប្រាក់ចំណេញរបស់ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ក៏គោរពផងដែរចំពោះបរិស្ថាន និងសហគមន៍ដែលយើងរស់នៅ ដោយអនុវត្តតាមទស្សនៈគ្រឹះសំខាន់ទាំងបី "មនុស្ស ផែនដី និងប្រាក់ចំណេញ" ហើយធ្វើការកំណត់ជានិច្ចនូវសូចនាករសម្រាប់វាស់វែង និងរាយការណ៍អំពីសកម្មភាព និងផលប៉ះពាល់ទៅលើសង្គម និងបរិស្ថាន ព្រមទាំងដើម្បីអនុវត្តនូវរចនាសម្ព័ន្ធរបាយការណ៍ ដោយផ្អែកជាចម្បងទៅលើការណែនាំក្នុងគំនិតផ្តួចផ្តើមនៃរបាយការណ៍ពិភពលោក (GRI) ។

# របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុ របស់ ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន")ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ។

## អំពីក្រុមហ៊ុន

ក្រុមហ៊ុនត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០២៧១៣ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ ។ ក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

## សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាឈ្មួញជើងសាមូលបត្រ និងសេវាផ្សេងទៀតដែលអនុម័តដោយគណៈកម្មការមូលបត្រកម្ពុជា (ហៅកាត់ថា "គ.ម.ក.") ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ប្រាក់(ខាត)/ចំណេញមុនដកពន្ធ | (៤៦.៥៥៧) | (១៨៨.៣២៣) | ៧៨.៤១៨ | ៣១៧.២០០ |
| ចំណេញ/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ៦.៣៤០ | ២៥.៦៤៥ | (១៥.៥៧៦) | (៦៣.០០៥) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | (៤០.២១៧) | (១៦២.៦៧៨) | ៦២.៨៤២ | ២៥៤.១៩៥ |

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភទេ ហើយក្រុមប្រឹក្សាភិបាលមិនបានស្នើឲ្យមានការបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទធ្វើរបាយការណ៍នេះទេ ។

## ដើមទុន

ពុំមានការប្រែប្រួលលើដើមទុនចុះបញ្ជី និងបានបង់ក្នុងអំឡុងការិយបរិច្ឆេទនេះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាភាព និងបំណុលផ្សេងទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន ៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និង នៅពេលដែលដល់ថ្ងៃកំណត់ ។

## ការផ្លាស់ប្តូរហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចនឹងបណ្តាលឲ្យតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈ

ជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបានបម្រើការនៅក្នុងឆ្នាំ និងនាថ្ងៃចេញរបាយការណ៍នេះមាន ៖

| | | |
|---|---|---|
| ១. | លោកស្រី ម៉ារ អមរា | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. | លោក ព្រំ វិសុទ្ធ | អភិបាល |
| ៣. | បណ្ឌិត ឡឹង សុភាព | អភិបាល |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ក្រុមហ៊ុន បានកាន់កាប់ដោយផ្ទាល់ទៅលើភាគហ៊ុនរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទនេះឡើយ ។

គិតត្រឹមចុងការិយបរិច្ឆេទ និងនៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយទិញយកភាគហ៊ុន ឬប័ណ្ណបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតនោះឡើយ ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុជាសារវន្តបានបង្ហាញនូវភាពត្រឹមត្រូវ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ យ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

(ខ) គោរពទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបស់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬ គ្មានជម្រើសសមរម្យផ្សេងទៀតក្រៅពីធ្វើបែបនេះ ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

នាងខ្ញុំសូមធ្វើការអនុម័តលើ របាយការណ៍ហិរញ្ញវត្ថុ ដែលបានបង្ហាញនៅទំព័រទី ២៦ ដល់ទី ៦៧ ដែលបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយ អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

*ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលៈ*

**លោកស្រី ម៉ារ អមរា**

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនភាគទុនិក ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី

### មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ ផ្សេងៗដែលបានបង្ហាញនៅទំព័រទី២៦ ដល់ទី ៦៧ ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ព្រមទាំង លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

### មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅ ក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំ ជឿជាក់ថា ភស្តុតាងសវនកម្មដែល យើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

### បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានធ្វើសវនកម្មដោយសវនករដទៃ ដែលបានបញ្ចេញមតិសវនកម្ម នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ ថារបាយការណ៍ហិរញ្ញវត្ថុនោះមានភាពត្រឹមត្រូវ ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាភិបាលដែលបង្ហាញនៅទំព័រទី ១៨ ដល់ទី ២១ ។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយ យើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានការបង្ហាញនូវកំហុងឆ្គងជាសារវន្ត ។ ប្រសិនបើការអានព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើង ខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងពីព័ត៌មានផ្សេងៗ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំ ពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថា មានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើ ពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះ

អំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោង លើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏ ៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារ តែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការ បង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណង ដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើមានភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋាន របស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។

- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀតវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**




ង៉ែ ហ៊ុយ

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | ៧ | ២៤៨.៨៨០ | ១.000.000 | ២៤៧.៧០៩ | ១.000.000 |
| ទ្រព្យសកម្មអរូបី | ៨ | ១៥.៤៨១ | ៦២.០៤២ | ៤.៨១២ | ១៩.៤២៦ |
| ទ្រព្យ និងបរិក្ខារ | ៩ | ១.៣៨៥ | ៥.៥៦៥ | ២.៩៤៥ | ១១.៨៨៩ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១០ (c) | ២៣.៩៦៣ | ៩៦.២៨៣ | ១៥.៤៩៨ | ៦២.៥៦៦ |
| **សរុបទ្រព្យសកម្មរយៈពេលវែង** | | ២៨៩.៦៦៩ | ១.១៦៣.៨៩០ | ២៧០.៩៦៤ | ១.០៩៣.៨៨១ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| ប្រាក់បញ្ញើមានកាលកំណត់ | ១១ | ១.៩៣៥.០១៥ | ៧.៧៧៤.៨៩០ | ១.៩២៤.៤៣៩ | ៧.៧៦៨.៩៦០ |
| ទ្រព្យសកម្មផ្សេងៗ | ១២ | ៣៥.៧៨១ | ១៤៣.៧៦៨ | ៣៥.២៣៤ | ១៤២.២៤០ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៣ | ១២.៣៣៨ | ៤៩.៥៧៤ | ៦៩.៤៧៩ | ២៨០.៤៨៧ |
| **សរុបទ្រព្យសកម្មរយៈពេលខ្លី** | | ១.៩៨៣.១៣៤ | ៧.៩៦៨.២៣២ | ២.០២៩.១៥២ | ៨.១៩១.៦៨៧ |
| **សរុបទ្រព្យសកម្ម** | | ២.២៧២.៨០៣ | ៩.១៣២.១២២ | ២.៣០០.១១៦ | ៩.២៨៥.៥៦៨ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | ២.០១០.000 | ៨.០៤០.000 | ២.០១០.000 | ៨.០៤០.000 |
| ប្រាក់ចំណេញរក្សាទុក | | ១៤០.៧៦៧ | ៥៦៥.៨៤៦ | ២00.៨៧១ | ៨០៨.៩៦៧ |
| ទុនបម្រុងផ្សេងៗ | | - | ៣៥.៩៣៦ | - | ៧៦.៣១៩ |
| **សរុបមូលធន** | | ២.១៥០.៧៦៧ | ៨.៦៤១.៧៨២ | ២.២១០.៨៧១ | ៨.៩២៥.២៨៦ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិក | ១៥ | ៥៩.០៣៩ | ២៣៧.២១៩ | ២១.២១៣ | ៨៥.៦៣៧ |
| | | ៥៩.០៣៩ | ២៣៧.២១៩ | ២១.២១៣ | ៨៥.៦៣៧ |
| **បំណុលរយៈពេលខ្លី** | | | | | |
| បង្គរ និងគណនីត្រូវទូទាត់ផ្សេងៗ | ១៦ | ៦២.៨៨៦ | ២៥២.៦៧៥ | ៤៩.៧៧៩ | ២00.៩៥៨ |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា | ១០(ក) | ១១១ | ៤៤៦ | ១៨.២៥៣ | ៧៣.៦៨៧ |
| | | ៦២.៩៩៧ | ២៥៣.១២១ | ៦៨.០៣២ | ២៧៤.៦៤៥ |
| **សរុបបំណុល** | | ១២២.០៣៦ | ៤៩០.៣៤០ | ៨៩.២៤៥ | ៣៦០.២៨២ |
| **សរុបមូលធន និងបំណុល** | | ២.២៧២.៨០៣ | ៩.១៣២.១២២ | ២.៣០០.១១៦ | ៩.២៨៥.៥៦៨ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| **ការបន្តប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណូល-ចំណូលកម្រៃនិងជើងសាសុទ្ធ | | ១២០.០៩២ | ៤៨៥.៧៧២ | ១៩៣.៨៨៨ | ៧៨៤.២៧៧ |
| ចំណូលការប្រាក់ | | ៩២.២២០ | ៣៧៣.០៣០ | ១១៥.៤០៩ | ៤៦៦.៨២៩ |
| ចំណេញ(ខាត)ផ្សេងៗសុទ្ធ | | ១.៥០៧ | ៦.០៩៦ | (៣៣) | (១៣៣) |
| | | ២១៣.៨១៩ | ៨៦៤.៨៩៨ | ៣០៩.២៦៤ | ១.២៥០.៩៧៣ |
| **ចំណាយ** | | | | | |
| ប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល | | ១៧១.៧១២ | ៦៩៤.៥៧៥ | ១១៩.២១៧ | ៤៨២.២៣៣ |
| ទឹក-ភ្លើង | | ៤.៣២០ | ១៧.៤៧៤ | ១៦.៨៦០ | ៦៨.១៩៩ |
| កម្រៃអាជ្ញាប័ណ្ណ | | ១៥.៤៧៩ | ៦២.៦១៣ | ១៥.៤១២ | ៦២.៣៤២ |
| ប្រាក់រង្វាន់ និងប្រាក់លើកទឹកចិត្ត | | ១៦.៦០០ | ៦៧.១៤៧ | ១៤.៤០៩ | ៥៨.២៨៣ |
| វិភាគទានមូលនិធិសោធននិវត្តន៍ | | - | - | ៩.២៦០ | ៣៧.៤៥៧ |
| កម្រៃផ្នែកច្បាប់ និងសេវាវិជ្ជាជីវៈ | | ៥.៥២២ | ២២.៣៣៦ | ៧.៣៩២ | ២៩.៩០១ |
| ទំនាក់ទំនង | | ៦.២២១ | ២៥.១៦៤ | ៧.៣២៨ | ២៩.៦៤២ |
| រំលស់ទ្រព្យសកម្មអរូបី | ៨ | ៤.៨១២ | ១៩.៤៦៥ | ៥.៩៤៥ | ២៤.០៤៨ |
| អត្ថប្រយោជន៍ពេលចូលនិវត្ត | ១៥ | ២.៤៧៥ | ១០.០១១ | ៤.០៥៦ | ១៦.៤០៧ |
| អត្ថប្រយោជន៍ផ្សេងៗ | | ២៦.១៧២ | ១០៥.៨៦៦ | ២៦.០៤០ | ១០៥.៣៣១ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | ១.៥៦០ | ៦.៣១០ | ១.០៦៧ | ៤.៣១៦ |
| ចំណាយផ្សេងៗ | | ៥.៥០៣ | ២២.២៦០ | ៣.៨៦០ | ១៥.៦១៤ |
| | | ២៦០.៣៧៦ | ១.០៥៣.២២១ | ២៣០.៨៤៦ | ៩៣៣.៧៧៣ |
| **(ខាត)ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | (៤៦.៥៥៧) | (១៨៨.៣២៣) | ៧៨.៤១៨ | ៣១៧.២០០ |
| ចំណូល/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ១០(ខ) | ៦.៣៤០ | ២៥.៦៤៥ | (១៥.៥៧៦) | (៦៣.០០៥) |
| **(ខាត)ចំណេញសុទ្ធក្នុងឆ្នាំ** | | (៤០.២១៧) | (១៦២.៦៧៨) | ៦២.៨៤២ | ២៥៤.១៩៥ |
| **ចំណូលលម្អិតផ្សេងៗ៖** | | | | | |
| *ខ្ទង់គណនីដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញ ក្នុងចំណេញ-ខាត៖* | | | | | |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកឡើងវិញ | ១៥ | (១៩.៨៨៧) | (៨០.៤៤៣) | (៩១៧) | (៣.៧០៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៤០.៣៨៣) | - | (៤៩៥) |
| ចំណូលលម្អិតផ្សេងៗក្នុងឆ្នាំ | | (១៩.៨៨៧) | (១២០.៨២៦) | (៩១៧) | (៤.២០៤) |
| ចំណូលលម្អិតសរុបក្នុងឆ្នាំ | | (៦០.១០៤) | (២៨៣.៥០៤) | ៦១.៩២៥ | ២៤៩.៩៩១ |
| **ប្រាក់ចំណេញរបស់៖** | | | | | |
| ម្ចាស់ក្រុមហ៊ុន | | (៤០.២១៧) | (១៦២.៦៧៨) | ៦២.៨៤២ | ២៥៤.១៩៥ |
| **ចំណូលលម្អិតសរុបរបស់៖** | | | | | |
| ម្ចាស់ក្រុមហ៊ុន | | (៦០.១០៤) | (២៨៣.៥០៤) | ៦១.៩២៥ | ២៤៩.៩៩១ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | ការបែងចែកទៅម្ចាស់ក្រុមហ៊ុន | | | | | | |
|---|---|---|---|---|---|---|---|
| | ដើមទុន | | ចំណេញរក្សាទុក | | ទុនបម្រុងផ្សេងៗ | សរុប | |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| សមតុល្យគិតត្រឹមថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៧ | ២.០១០.០០០ | ៨.០៤០.០០០ | ១៣៨.៩៤៦ | ៥៥៨.៤៨១ | ៧៦.៨១៤ | ២.១៤៨.៩៤៦ | ៨.៦៧៥.២៩៥ |
| *ចំណូលលម្អិត៖* | | | | | | | |
| ចំណេញក្នុងឆ្នាំ | - | - | ៦២.៨៤២ | ២៥៤.១៩៥ | - | ៦២.៨៤២ | ២៥៤.១៩៥ |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកឡើងវិញ | - | - | (៩១៧) | (៣.៧០៩) | - | (៩១៧) | (៣.៧០៩) |
| ចំណូលលម្អិតផ្សេងៗ-លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (៤៩៥) | - | (៤៩៥) |
| ចំណូលលម្អិតក្នុងឆ្នាំសរុប | - | - | ៦១.៩២៥ | ២៥០.៤៨៦ | (៤៩៥) | ៦១.៩២៥ | ២៤៩.៩៩១ |
| សមតុល្យគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧ | ២.០១០.០០០ | ៨.០៤០.០០០ | ២០០.៨៧១ | ៨០៨.៩៦៧ | ៧៦.៣១៩ | ២.២១០.៨៧១ | ៨.៩២៥.២៨៦ |

| | ការទទួលខុសត្រូវចំពោះម្ចាស់ក្រុមហ៊ុន | | | | | | |
|---|---|---|---|---|---|---|---|
| | ដើមទុន | | ចំណេញរក្សាទុក | | ទុនបម្រុងផ្សេងៗ | សរុប | |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| សមតុល្យគិតត្រឹមថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៨ | ២.០១០.០០០ | ៨.០៤០.០០០ | ២០០.៨៧១ | ៨០៨.៩៦៧ | ៧៦.៣១៩ | ២.២១០.៨៧១ | ៨.៩២៥.២៨៦ |
| *ចំណូលលម្អិត៖* | | | | | | | |
| ចំណេញក្នុងឆ្នាំ | - | - | (៤០.២១៧) | (១៦២.៦៧៨) | - | (៤០.២១៧) | (១៦២.៦៧៨) |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកឡើងវិញ | - | - | (១៩.៨៨៧) | (៨០.៤៤៣) | - | (១៩.៨៨៧) | (៨០.៤៤៣) |
| ចំណូលលម្អិតផ្សេងៗ-លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (៤០.៣៨៣) | | (៤០.៣៨៣) |
| ចំណូលលម្អិតក្នុងឆ្នាំសរុប | - | - | (៦០.១០៤) | (២៤៣.១២១) | (៤០.៣៨៣) | (៦០.១០៤) | (២៨៣.៥០៤) |
| សមតុល្យគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ | ២.០១០.០០០ | ៨.០៤០.០០០ | ១៤០.៧៦៧ | ៥៦៥.៨៤៦ | ៣៥.៩៣៦ | ២.១៥០.៧៦៧ | ៨.៦៤១.៧៨២ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (៤៦.៥៥៧) | (១៨៨.៣២៣) | ៧៨.៤១៨ | ៣១៧.២០០ |
| *និយ័តកម្ម ៖* | | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | ១.៥៦០ | ៦.៣១០ | ១.០៦៧ | ៤.៣១៦ |
| រំលស់ទ្រព្យសកម្មអរូបី | ៨ | ៤.៨១២ | ១៩.៤៦៥ | ៥.៩៤៥ | ២៤.០៤៨ |
| ចំណូលការប្រាក់ | | (៩២.២២០) | (៣៧៣.០៣០) | (១១៥.៤០៩) | (៤៦៦.៨២៩) |
| ចំណាយអត្ថប្រយោជន៍បុគ្គលិក | ១៥(ក) | ២.៤៧៥ | ១០.០១១ | ៤.០៥៦ | ១៦.៤០៧ |
| សំណងអតីតភាពការងារ | ១៥(ខ) | ១៥.៤៦៤ | ៦២.៥៥២ | - | - |
| ចំណេញពីការប្តូររូបិយប័ណ្ណមិនទាន់ទទួលស្គាល់ | | (១.១៧១) | (៤.៧៣៧) | - | - |
| *បម្រែបម្រួលដើមទុនបង្វិល ៖* | | | | | |
| ទ្រព្យសកម្មផ្សេងៗ | | (៥៤៧) | (២.២១៣) | (៥.០៧២) | (២០.៥១៦) |
| បង្គរ និងគណនីត្រូវទូទាត់ផ្សេងៗ | | ១៣.១០៧ | ៥៣.០១៨ | ២២.៩៥៧ | ៩២.៨៦១ |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | | (១០៣.០៧៧) | (៤១៦.៩៤៧) | (៨.០៣៨) | (៣២.៥១៣) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១០(ក) | (២០.២៦៧) | (៨១.៩៨០) | (៩.៦៩៩) | (៣៩.២៣២) |
| លំហូរសាច់ប្រាក់ចេញពីសកម្មភាពប្រតិបត្តិការ-សុទ្ធ | | (១២៣.៣៤៤) | (៤៩៨.៩២៧) | (១៧.៧៣៧) | (៧១.៧៤៥) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | (២.១០៥) | (៨.៥១៥) |
| ការទិញទ្រព្យសកម្មអរូបី | | (១៥.៤៩១) | (៦២.៤៥៩) | - | - |
| ប្រាក់បញ្ញើមានកាលកំណត់ | | (២០.០០០) | (៨០.៩០០) | (១៥០.០០០) | (៦០៦.៧៥០) |
| ការប្រាក់បានទទួល | | ១០១.៦៩៤ | ៤១១.៩៥០ | ១២៣.៨៨២ | ៤៩៩.៤៨៥ |
| លំហូរសាច់ប្រាក់ចូល/(ចេញ) ពីសកម្មភាពវិនិយោគ-សុទ្ធ | | ៦៦.២០៣ | ២៦៧.៧៩១ | (២៨.៦២៣) | (១១៥.៧៨០) |
| **តំហយសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៥៧.១៤១) | (២៣១.១៣៦) | (៤៦.៣៦០) | (១៨៧.៥២៥) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ** | | ៦៩.៤៧៩ | ២៨០.៤៨៧ | ១១៥.៨៣៩ | ៤៦៧.៦៤២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ២២៣ | - | ៣៧០ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ១៣ | ១២.៣៣៨ | ៤៩.៥៧៤ | ៦៩.៤៧៩ | ២៨០.៤៨៧ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# កំណត់សម្គាល់លើរបាយការណ៍

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

## ១. អំពីក្រុមហ៊ុន

ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០២៧១៣ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ ។ ក្រុមហ៊ុន ត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុនមេ”) ។

ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការជាឈ្មួញជើងសាមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជាពីគណៈកម្មការមូលបត្រកម្ពុជា ហៅកាត់ថា (“គ.ម.ក.”)នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ ។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាឈ្មួញជើងសាមូលបត្រ និងសេវាផ្សេងទៀតដែលអនុម័តដោយ គ.ម.ក. ។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានអាសយដ្ឋាន ស្ថិតនៅអគារលេខ៦១ ជាន់ទី៥ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ក្រុមហ៊ុនមានបុគ្គលិកសរុបចំនួន ៨ នាក់ (២០១៧: ៧ នាក់) ។

## ២. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”ឬ “ស.រ.ទ.ហ.អ.ក”)។

នេះគឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុន ដែលបានប្រើប្រាស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRS”ឬ “ស.រ.ហ.អ.ក”) ១៥ ស្តីពីចំណូលពីកិច្ចសន្យាជាមួយអតិថិជន និង ស.រ.ហ.អ.ក ៩ ស្តីពីឧបករណ៍ហិរញ្ញវត្ថុ ។ ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យសំខាន់ៗ ត្រូវបានពន្យល់នៅកំណត់សម្គាល់ ៤ ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់សិទ្ធិឲ្យចេញផ្សាយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ។

### (ខ) មូលដ្ឋានទូទៅនៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋានតម្លៃដើមដំបូង ។

### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីបំពេញតាមតម្រូវការដែលមានចែងនៅក្នុងច្បាប់គណនេយ្យ និង សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសផ្សេងៗ ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណគោល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនេះ ។ ចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណ ដែលបណ្តាលមកពីការទូទាត់តាមបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានកត់ត្រាក្នុងចំណេញ ឬខាត ។

## (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្មបំណុល ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែង អាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើការប៉ាន់ស្មាន ត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទស្សនវិស័យ ។

### *ការវាស់វែងតម្លៃសមស្រប*

គោលនយោបាយគណនេយ្យ និងការលាតត្រដាងព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុន តម្រូវឲ្យមានការវាស់វែងតាមតម្លៃសមស្របទាំងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ។

អ្នកគ្រប់គ្រង ធ្វើការត្រួតពិនិត្យលើការបញ្ចូលទិន្នន័យ ដែលមិនអាចសង្កេតបានសំខាន់ៗ និងនិយ័តភាពលើការវាស់វែងតម្លៃ ។ ប្រសិនបើព័ត៌មានភាគីទីបី ដូចជា សម្រង់តម្លៃពីឈ្មួញជើងសា ឬសេវាកម្មផ្តល់តម្លៃត្រូវបានប្រើសម្រាប់ការវាស់វែងតម្លៃសមស្របនោះ ក្រុមការងារហិរញ្ញវត្ថុ នឹងវាយតម្លៃលើភស្តុតាងដែលបានមកពីភាគីទីបី ដើម្បីផ្តល់ជាអំណះអំណាងដល់ការសន្និដ្ឋានថាតើការវាយតម្លៃនោះត្រឹមត្រូវទៅតាម "ស.រ.ទ.ហ.អ.ក" ដោយរួមបញ្ចូលទាំងឋានានុក្រម នៃតម្លៃសមស្រប ដែលការវាយតម្លៃទាំងនោះត្រូវបានចាត់ថ្នាក់ ។

នៅពេលវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុល ក្រុមហ៊ុនបានប្រើព័ត៌មានទីផ្សារដែលអាចអង្កេតបានកាន់តែច្រើនតាមតែអាចធ្វើបាន ។ តម្លៃសមស្រប ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នាតាមឋានានុក្រម ដោយយោងទៅលើទិន្នន័យដែលប្រើប្រាស់ក្នុងវិធីសាស្ត្រវាយតម្លៃ ដូចខាងក្រោម៖

- កម្រិតទី ១ : តម្លៃដកស្រង់ (មិនទាន់មាននិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលស្រដៀងគ្នា ។
- កម្រិតទី ២: ទិន្នន័យដែលមិនមែនជាតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី ១ ដែលអាចធ្វើការអង្កេត បានសម្រាប់ទ្រព្យសកម្ម ឬបំណុល ទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬដោយប្រយោល (ឧទាហរណ៍កើតចេញពីតម្លៃ) ។
- កម្រិតទី ៣: ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យទីផ្សារ ដែលអាចអង្កេតបាន (ទិន្នន័យមិនអាចអង្កេតបាន) ។

ប្រសិនបើទិន្នន័យដែលបញ្ចូល ដើម្បីវាយតម្លៃនូវតម្លៃសមស្របនៃ ទ្រព្យសកម្ម ឬបំណុល ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នាតាមឋានានុក្រមតម្លៃសមស្រប នោះការវាស់វែងតម្លៃសមស្របត្រូវបានចាត់ថ្នាក់ស្ថិតនៅក្នុងកម្រិតដូចគ្នានៃឋានានុក្រមតម្លៃទាំងមូល ក៏ដូចជាការបញ្ចូលទិន្នន័យកម្រិតទាបបំផុតសំខាន់ៗ សម្រាប់ការវាស់វែងទាំងមូលដែរ ។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេរផ្សេងៗរវាងកម្រិតនៃតម្លៃសមស្រប នាចុងការិយបរិច្ឆេទនៃរបាយការណ៍ក្នុងអំឡុងពេលកែប្រែដែលបានកើតឡើង ។

ព័ត៌មានពីការសន្មត ក្នុងការវាស់វែងតម្លៃសមស្រប ត្រូវបានបញ្ចូលនៅក្នុងកំណត់សម្គាល់ ១៨ ឧបករណ៍ហិរញ្ញវត្ថុ តម្លៃសមស្រប និងការគ្រប់គ្រងហានិភ័យ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ

ក្រុមហ៊ុនបានប្រើប្រាស់គោលនយោបាយគណនេយ្យដែលមានដូចខាងក្រោម នៅគ្រប់ការិយបរិច្ឆេទទាំងអស់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះប្រកបដោយសង្គតិភាព ។

### (ក) ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។

សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ នាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ក៏ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍ ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណបរទេស ដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅក្នុងរបាយការណ៍លទ្ធផល ។ ទ្រព្យដែលមិនមែនជារូបិយវត្ថុបានវាស់តាមការចំណាយជាប្រវត្តិសាស្ត្រនៅក្នុងរូបិយប័ណ្ណផ្សេងទៀត ដែលត្រូវបានបកប្រែដោយប្រើអត្រាតម្លៃរូបិយប័ណ្ណតាមកាលបរិច្ឆេទនីមួយៗនៃប្រតិបត្តិការដំបូង ។

### (ខ) ឧបករណ៍ហិរញ្ញវត្ថុ

*(i) ការទទួលស្គាល់ និងការវាស់វែងដំបូង*

គណនីអតិថិជន ត្រូវបានទទួលស្គាល់ដំបូងនៅពេលប្រតិបត្តិការកើតឡើង ។ គ្រប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុទាំងអស់ ត្រូវបានទទួលស្គាល់ដំបូងនៅពេលដែលក្រុមហ៊ុនបានក្លាយជាភាគីនៃការផ្តល់កិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ ។

ទ្រព្យសកម្មហិរញ្ញវត្ថុ (លុះត្រាតែវាជាគណនីអតិថិជនដែលគ្មានសមាសភាគហិរញ្ញប្បទានជាសារវន្ត) ឬ បំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងដំបូងតាមតម្លៃសមស្របបូកនឹងសម្រាប់ធាតុដែលវាស់វែងតាមតម្លៃសមស្របតាមការចំណេញ ឬខាត ("FVTPL") ចំណាយប្រតិបត្តិការដែលរួមចំណែកដោយផ្ទាល់ទៅលើការទិញ-លក់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ ។ គណនីអតិថិជនដែលមិនមានសមាសភាគហិរញ្ញប្បទានជាសារវន្ត គឺត្រូវបានវាស់វែងដំបូងតាមតម្លៃប្រតិបត្តិការ ។

*(ii) ចំណាត់ថ្នាក់ និងការវាស់វែងបន្ទាប់*

*ទ្រព្យសកម្មហិរញ្ញវត្ថុ - ចំណាត់ថ្នាក់ - គោលនយោបាយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨*

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុបានបែងចែកថ្នាក់ទៅតាមការវាស់វែង ៖ រំលស់ថ្លៃដើម តម្លៃសមស្របតាមលទ្ធផលលម្អិតផ្សេងៗ (FVOCI) ឬតម្លៃសមស្របតាមចំណេញ ឬខាត ("FVTPL") ។

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានចាត់ថ្នាក់ឡើងវិញនៅពេលបន្ទាប់ ឬទៅលើការទទួលស្គាល់ដំបូងនោះទេ លុះត្រាតែក្រុមហ៊ុនបានផ្លាស់ប្តូរគំរូអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ដែល

ក្នុងករណីនោះ ផ្នែកទាំងអស់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលប៉ះពាល់ ត្រូវចាត់ថ្នាក់ឡើងវិញនៅថ្ងៃទីមួយ អំឡុងពេល របាយការណ៍ដំបូង បន្ទាប់ពីមានការផ្លាស់ប្តូរគំរូអាជីវកម្ម ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងទៅតាមថ្លៃដើម បើសិនជាវាបំពេញទៅនឹងលក្ខខណ្ឌខាងក្រោម ហើយមិនបានកំណត់ថាជា FVTPL :

- វាត្រូវបានធ្វើឡើងនៅក្នុងគំរូអាជីវកម្មមួយ ដែលមានគោលដៅកាន់កាប់ទ្រព្យសកម្មដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យានិង
- លក្ខខណ្ឌកិច្ចសន្យារបស់ខ្លួនផ្តល់នូវលំហូរសាច់ប្រាក់តាមកាលបរិច្ឆេទជាក់លាក់ ដើម្បីទទួលការទូទាត់នូវប្រាក់ដើម និងការប្រាក់លើចំនួនប្រាក់ដើមដែលនៅសល់ ។

ការវិនិយោគបំណុលត្រូវបានវាស់នៅ FVOCI ប្រសិនបើវាឆ្លើយតបនឹងលក្ខខណ្ឌដូចខាងក្រោម និងមិនត្រូវបានកំណត់ជា FVTPL :

- វាត្រូវបានធ្វើឡើងនៅក្នុងគំរូអាជីវកម្មមួយ ដែលគោលបំណងរបស់វាត្រូវបានសម្រេចដោយការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- កិច្ចសន្យានៃកិច្ចសន្យារបស់ខ្លួន ផ្តល់ឲ្យកើនឡើងលើកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលជាការទូទាត់តែលើប្រាក់ដើមនិងការប្រាក់ទៅលើចំនួនដើមដែលនៅសល់ ។

ទៅលើការទទួលស្គាល់បឋមនៃការវិនិយោគមូលធនដែលមិនបានកាន់កាប់សម្រាប់ជួញដូរ ក្រុមហ៊ុនត្រូវជ្រើសរើស ដើម្បីបង្ហាញពីការប្រែប្រួលតម្លៃសមស្របក្នុង OCI ។ ជម្រើសនេះ ត្រូវបានធ្វើឡើងតាមការវិនិយោគនីមួយៗ ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ដែលមិនបានចាត់ថាជាការវាស់វែងតាមរំលស់តម្លៃដើមដូចបានរៀបរាប់ខាងលើ ដែលត្រូវបានវាស់វែងនៅ FVTPL នេះបានរួមបញ្ចូល និស្សន្ទឧបករណ៍ហិរញ្ញវត្ថុទាំងអស់ ។ ក្នុងការទទួលស្គាល់បឋម ក្រុមហ៊ុនអាចជ្រើសរើសទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញលក្ខខណ្ឌដើម្បីវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI ឬជា FVPTL ប្រសិនបើធ្វើដូច្នេះនឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នាដែលអាចកើតមានឡើង ។

*<u>ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាយតម្លៃគំរូអាជីវកម្ម៖ គោលនយោបាយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨</u>*

ក្រុមហ៊ុនធ្វើការវាយតម្លៃ គោលដៅអាជីវកម្មក្នុងនោះទ្រព្យសកម្មត្រូវបានរក្សាទុកជាក្រុមនៃការវិនិយោគ ពីព្រោះវាបានឆ្លុះបញ្ចាំងអំពីការរៀបចំរបៀបនៃអាជីវកម្ម ដែលបានចាត់ចែងព័ត៌មានដែលបានផ្តល់ជូនដល់អ្នកគ្រប់គ្រង ។ ព័ត៌មានដែលបានពិចារណារួមមាន៖

- គោលនយោបាយ និងគោលដៅដែលបានកំណត់រួចហើយសម្រាប់ក្រុមនៃការវិនិយោគ និងប្រតិបត្តិការ នៃគោលនយោបាយក្នុងការអនុវត្ត
- សកម្មភាពអាជីវកម្មនៃក្រុមវិនិយោគដែលបានវាយតម្លៃ និងរាយការណ៍ឲ្យអ្នកគ្រប់គ្រងក្រុមហ៊ុន
- ហានិភ័យដែលប៉ះពាល់ទៅលើសកម្មភាពគំរូអាជីវកម្ម (ហើយទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកាន់កាប់ក្រោមគំរូអាជីវកម្ម) និងយុទ្ធសាស្ត្ររបស់ខ្លួនអំពីរបៀបគ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មត្រូវបានផ្តល់អត្ថប្រយោជន៍ (ឧទាហរណ៍ ថាតើត្រូវបានផ្តល់ប្រយោជន៍ទៅតាមតម្លៃសមស្របនៃទ្រព្យសកម្មដែលបានចាត់ចែង ឬតាមលំហូរសាច់ប្រាក់ដែលប្រមូលបាន) និង

- ភាពញឹកញាប់ និងពេលវេលានៃការលក់នៅក្នុងការិយបរិច្ឆេទមុនហេតុផលនៃការលក់បែបនោះ និង ការរំពឹងទុករបស់ខ្លួនអំពីសកម្មភាពលក់នាពេលអនាគត ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលរក្សាទុកសម្រាប់ការជួញដូរឬការគ្រប់គ្រង ហើយការវាយតម្លៃលទ្ធផលផ្អែកលើមូលដ្ឋានតម្លៃសមស្របត្រូវបានវាស់នៅ FVTPL ។

*ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺដើម្បីទទួលការទូទាត់ប្រាក់ដើម និងការប្រាក់ប៉ុណ្ណោះ (SPPI) -គោលនយោបាយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨*

សម្រាប់គោលបំណងនៃការវាយតម្លៃ “ប្រាក់ដើម” ត្រូវបានកំណត់ជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលទទួលស្គាល់ដំបូង ។ “ការប្រាក់” ត្រូវបានកំណត់ជាតម្លៃតបស្នងនៃតម្លៃពេលវេលា និងសម្រាប់ហានិភ័យឥណទាន ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងចំនួនប្រាក់ដើមដែលនៅសល់ក្នុងអំឡុងពេលជាក់លាក់ណាមួយ និងហានិភ័យការផ្តល់ប្រាក់កម្ចីមូលដ្ឋានផ្សេងទៀត (ដូចជា ហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល) ក៏ដូចជាកម្រិតប្រាក់ចំណេញ ។

ក្នុងការវាយតម្លៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាជា SPPI នោះ ក្រុមហ៊ុនធ្វើការពិចារណាលក្ខខណ្ឌនៃកិច្ចសន្យានៃឧបករណ៍នោះ ។ នេះរួមបញ្ចូលទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួននៃលំហូរសាច់ប្រាក់តាមកិច្ចសន្យា ក្នុងករណីនេះវានឹងមិនបំពេញលក្ខខណ្ឌនេះឡើយ ។

ក្នុងការវាយតម្លៃនេះក្រុមហ៊ុនពិចារណាលើ៖

- ព្រឹត្តិការណ៍ដែលនឹងផ្លាស់ប្តូរចំនួនទឹកប្រាក់ និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខខណ្ឌដែលអាចកែតម្រូវអត្រាគូប៉ុងតាមកិច្ចសន្យារួមទាំងលក្ខណៈពិសេសនៃអត្រាអថេរ
- ការទូទាត់មុន និងលក្ខណៈពិសេសបន្ថែម និង
- លក្ខខណ្ឌដែលកំណត់ការអះអាងរបស់ក្រុមហ៊ុនចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ឧទាហរណ៍ លក្ខណៈមិនអាចទូទាត់បាន)

លក្ខណៈនៃការទូទាត់ជាមុន គឺស្របជាមួយនឹង SPPI ប្រសិនបើចំនួននៃការទូទាត់មុនជាសារវន្តតំណាងឲ្យចំនួនទឹកប្រាក់ដែលមិនទាន់បង់ និងការប្រាក់ទៅលើចំនួនប្រាក់ដើមដែលមិនទាន់ទូទាត់ដែលអាចរាប់បញ្ចូលនូវសំណងបន្ថែមសម្រាប់ការបញ្ចប់កិច្ចសន្យាមុន ។

*ទ្រព្យសកម្មហិរញ្ញវត្ថុ-ការវាស់វែងបន្ទាប់ និងចំណេញ ឬខាត៖ គោលនយោបាយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨*

*ទ្រព្យសកម្មហិរញ្ញវត្ថុនៅ FVTPL*

ទ្រព្យសកម្មទាំងនេះត្រូវបានវាស់វែងបន្ទាប់ទៅតាមតម្លៃសមស្រប ។ ចំណេញ ឬការខាតបង់សុទ្ធរួមទាំងការប្រាក់ ឬចំណូលភាគលាភត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។

*ទ្រព្យសកម្មហិរញ្ញវត្ថុតាមរំលស់ថ្លៃដើម*

ទ្រព្យសកម្មទាំងនេះ ត្រូវបានវាស់វែងបន្ទាប់ទៅតាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។ រំលស់ថ្លៃដើម ត្រូវបានកាត់បន្ថយដោយឱនភាពនៃតម្លៃ ។ ចំណូលការប្រាក់ ចំណេញខាត ឬការខាតបង់ពីការប្តូរប្រាក់បរទេស និងឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត ។

*ការវិនិយោគមូលធនវាស់វែងតាម FVOCI*

ទ្រព្យសកម្មទាំងនេះត្រូវបានវាស់វែងបន្ទាប់ទៅតាមតម្លៃសមស្រប ។ ភាគលាភត្រូវបានទទួលស្គាល់ជាប្រាក់ចំណូលក្នុងចំណេញ ឬខាត លុះត្រាតែភាគលាភបានបង្ហាញយ៉ាងច្បាស់ពីការងើបឡើងវិញពីផ្នែកចំណាយនៃការវិនិយោគ ។ ការចំណេញ និងការខាតបង់សុទ្ធផ្សេងទៀតត្រូវបានទទួលស្គាល់នៅក្នុង OCI ហើយមិនត្រូវបានផ្ទេរជាចំណេញ ឬខាតនោះទេ ។

*ទ្រព្យសកម្មហិរញ្ញវត្ថុ - គោលនយោបាយអនុវត្តមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨*

ក្រុមហ៊ុន បានចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមចាត់ថ្នាក់ដូចខាងក្រោម ៖ ទ្រព្យសកម្មហិរញ្ញវត្ថុរក្សាទុករហូតដល់កាលកំណត់ឥណទាន និងគណនីត្រូវទទួល និងទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ ។

*ទ្រព្យសកម្មហិរញ្ញវត្ថុ - ការចាត់ថ្នាក់ ការវាស់វែងជាបន្តបន្ទាប់ និងការចំណេញ និងការខាត៖ គោលនយោបាយអនុវត្តមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨*

### *ឥណទាន និងគណនីត្រូវទទួល*

ឥណទាន និងគណនីត្រូវទទួល ត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការពាក់ព័ន្ធ ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង វាត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

### *សាច់ប្រាក់ និងសាច់ប្រាក់សមមូល*

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសមតុល្យសាច់ប្រាក់ សមតុល្យធនាគារ និងប្រាក់បញ្ញើជាមួយធានាគារតាមតម្រូវការដែលមានកាលកំណត់ ៣ ខែ ឬតិចជាង គិតចាប់ពីថ្ងៃដែលបានទទួល ហើយដែលអាចប្តូរជាសាច់ប្រាក់ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ហើយត្រូវបានប្រើដោយក្រុមហ៊ុនក្នុងការសន្យាទូទាត់រយៈពេលខ្លី ។

*បំណុលហិរញ្ញវត្ថុ - ការចាត់ថ្នាក់ ការវាស់វែងជាបន្តបន្ទាប់ និងការចំណេញ និងការខាត៖ គោលនយោបាយអនុវត្តដោយមិនមានការផ្លាស់ប្តូរមុន និងចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨*

### *បំណុលហិរញ្ញវត្ថុផ្សេងៗ*

បំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការពាក់ព័ន្ធផ្សេងៗ ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង បំណុលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។ ចំណាយការប្រាក់ និងប្រាក់ចំណេញ និងខាតលើការប្តូររូបិយប័ណ្ណបរទេស ត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬខាត ។ ប្រាក់ចំណេញ ឬខាតណាមួយលើការមិនទទួលស្គាល់ ត្រូវបានទទួលស្គាល់ផងដែរនៅក្នុងប្រាក់ចំណេញ ឬខាត ។

*(iii) ការឈប់ទទួលស្គាល់*

ក្រុមហ៊ុន ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬក្រុមហ៊ុនបានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ ទាំងមិនផ្ទេរចេញ ឬទាំងមិនរក្សាហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុ និងមិនរក្សាការគ្រប់គ្រងទៅលើទ្រព្យសកម្មដែលផ្ទេរចេញ ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចសន្យាត្រូវបានបញ្ចប់ លុបចោល ឬផុតកាលកំណត់ ។ ក្រុមហ៊ុនក៏ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ ពេលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែមានភាពខុសគ្នាខ្លាំង ក្នុងករណីនេះបំណុលហិរញ្ញវត្ថុថ្មី ដោយផ្អែកលើលក្ខខណ្ឌដែលបានកែប្រែ ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប ។

នៅពេលឈប់ទទួលស្គាល់នូវបំណុលហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុ និងតម្លៃដែលត្រូវបង់ (រួមទាំងទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ដែលបានផ្ទេរ ឬបំណុលដែលបានទទួល) ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។

*(iv) ការកាត់កង*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃយោងសុទ្ធត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងធ្វើការទូទាត់ លើមូលដ្ឋានតម្លៃសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលជាប្រចាំ ។

## (គ) ដើមទុន - ភាគហ៊ុនធម្មតា

ថ្លៃដើមកើតឡើងដោយផ្ទាល់ពីការបោះផ្សាយភាគហ៊ុនធម្មតា ដកផលប៉ះពាល់នៃពន្ធត្រូវបានទទួលស្គាល់ដោយកាត់ពីមូលធន ។

## (ឃ) ទ្រព្យ និងបរិក្ខារ

*(i) ការទទួលស្គាល់ និងការវាស់វែង*

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានវាស់វែងតាមតម្លៃដើមដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។

ថ្លៃដើម គឺត្រូវបានរួមបញ្ចូលនូវរាល់ចំណាយដែលផ្ទេរទៅក្នុងការទិញទ្រព្យសកម្ម ។ ការទិញប្រព័ន្ធផ្នែកទន់ (software) សម្រាប់បង្កើតរួមជាសមាធាតុមួយរបស់បរិក្ខារ ត្រូវបានកត់ត្រាជាផ្នែកមួយនៃបរិក្ខារនោះ ។

ប្រសិនបើផ្នែកសារវន្តណាមួយនៃទ្រព្យ គ្រឿងចក្រ និងបរិក្ខារទាំងនោះមានអាយុកាលប្រើប្រាស់ខុសពីគ្នា សមាសធាតុនោះ ត្រូវបានដាក់ជាផ្នែកដោយឡែក (សមាសភាពចម្បង) នៃទ្រព្យ គ្រឿងចក្រ និងបរិក្ខារ ។

ចំណេញ ឬខាតពីការលក់ ផ្នែកនៃទ្រព្យ គ្រឿងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណេញ ឬ ខាតនៅក្នុងរបាយការណ៍ចំណេញ ឬ ខាត ។

*(ii) ការចំណាយបន្ទាប់*

ការចំណាយបន្តបន្ទាប់ត្រូវបានធ្វើមូលធនកម្ម ប្រសិនបើ ចំណាយនោះនឹងផ្តល់នូវលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ក្រុមហ៊ុន ។ ការបន្តថែទាំ និងជួសជុស ត្រូវបានចំណាយនៅពេលកើតឡើង ។

*(iii) រំលស់*

រំលស់ ត្រូវបានគណនាដើម្បីលុបចោលថ្លៃដើមនៃទ្រព្យ និងបរិក្ខារ ដកចេញនូវតម្លៃកាកសំណល់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ តាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាន និងត្រូវទទួលស្គាល់ជាចំណេញ ឬ ខាតនៅក្នុងរបាយការណ៍ចំណេញ ឬ ខាត ។

អាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យ និងបរិក្ខារមាន ដូចខាងក្រោម៖

| | |
|---|---|
| គ្រឿងសង្ហារឹម គ្រឿងបំពាក់ និងសម្ភារការិយាល័យ | ៣ ឆ្នាំ |
| សម្ភារកុំព្យូទ័រ | ៣ ឆ្នាំ |

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប ។

## (ង) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានកម្មវិធីកុំព្យូទ័រ អាជ្ញាប័ណ្ណផ្តល់ដោយ គ.ម.ក. និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានបង្ហាញតាមថ្លៃដើម ។ កម្មវិធីកុំព្យូទ័រមានអាយុកាលប្រើប្រាស់ជាក់លាក់ និងត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ ។ រំលស់ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីបែងចែកថ្លៃដើមនៃកម្មវិធីកុំព្យូទ័រលើរយៈពេល ៥ ឆ្នាំ ។

អាជ្ញាប័ណ្ណផ្តល់ដោយ គ.ម.ក. ត្រូវបានចាត់ទុកថាជាសិទ្ធិធ្វើប្រតិបត្តិការអាជីវកម្មបម្រើសេវាជាឈ្មួញជើងសា ក្នុងផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា “ផ.ម.ក”) ។ ថ្លៃដើមដែលបានកើតឡើង និងបានបង់ជូន គ.ម.ក. សម្រាប់ថ្លៃអាជ្ញាប័ណ្ណ ត្រូវបានដករំលស់ក្នុងរយៈពេលនៃអាយុកាលរបស់អាជ្ញាប័ណ្ណ គឺមានរយៈពេលបីឆ្នាំ ។

## (ច) ឱនភាពនៃតម្លៃ

### (i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ

*គោលនយោបាយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨*

ក្រុមហ៊ុនទទួលស្គាល់សំវិធានធនលើការខាតលើឥណទានរំពឹងថាបាត់បង់ (ECL) សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ វាស់វែងតាមរំលស់ថ្លៃដើម ។

ក្រុមហ៊ុនវាស់វែងការខាតបង់គណនីអតិថិជន លើចំនួនដែលស្មើនឹងការខាតពេញអាយុកាលនៃឥណទាន (Life time ECL) លើកលែងតែសាច់ប្រាក់ និងសាច់ប្រាក់សមមូល ដែលហានិភ័យឥណទាន (ពោល គឺហានិភ័យនៃការខាតបង់កើតឡើងក្នុងរយៈពេលរំពឹងទុកនៃអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុ) មិនបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់ដំបូងដែលត្រូវបានវាស់វែងនៅ ECL ១២ ខែ ។ សំវិធានធន ការខាតបង់សម្រាប់គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានវាស់វែងនៅចំនួនមួយដែលស្មើនឹង ECL ពេញអាយុកាល ។

នៅពេលមានការកំណត់ថា ហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុមានការកើនឡើងជាសារវន្តតាំងពីពេលទទួលស្គាល់លើកដំបូង និងនៅពេលដែលធ្វើការប៉ាន់ស្មាន (ECL) ក្រុមហ៊ុនពិចារណាលើព័ត៌មាន ដែលសមហេតុផល និងមានឯកសារគាំទ្រដែលពាក់ព័ន្ធ និងអាចរកបានដោយមិនត្រូវការចំណាយហួសជ្រុល ឬក៏ត្រូវការប្រឹងប្រែងខ្លាំង ។ នេះរួមបញ្ចូលទាំងបរិមាណ និងគុណភាពព័ត៌មាន

និងការវិភាគដោយយោងទៅតាមបទពិសោធន៍របស់ក្រុមហ៊ុន និងការកំណត់តម្លៃឥណទានដែលបានដឹងរួមទាំងព័ត៌មាន នាពេលអនាគត ។

ក្រុមហ៊ុនសន្មតថាហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុ មានការកើនឡើងជាសារវន្ត ប្រសិនបើហួសកាលកំណត់សងលើសពី ៣០ ថ្ងៃ ។ ក្រុមហ៊ុនពិចារណាថាទ្រព្យសកម្មហិរញ្ញវត្ថុមានការសងយឺតយ៉ាវនៅពេលដែល ៖

- អ្នកខ្ចីទំនងនឹងមិនទូទាត់សងឥណទានឲ្យទៅក្រុមហ៊ុនក្នុងតម្លៃពេញ ដោយគ្មានគ្រឿងជួយដោះបន្ទាល់ពីក្រុមហ៊ុន ដូចជាការដាក់លក់វត្ថុធានា (ប្រសិនបើមាន) ឬ
- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលហួសកាលកំណត់សងលើសពី ៩០ ថ្ងៃ ។

ECL ពេញអាយុកាល គឺ ECL ដែលកើតចេញលទ្ធផលព្រឹត្តិការណ៍ក្នុងការសងយឺតយ៉ាវទាំងឡាយណាដែលអាចកើតមានក្នុងអាយុកាលដែលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ ។

ECL ១២ ខែ គឺជាចំណែកនៃ ECL ដែលលទ្ធផលចេញពីព្រឹត្តិការណ៍សងយឺតយ៉ាវដែលអាចកើតឡើងក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ (ឬក្នុងរយៈពេលខ្លីជាង ប្រសិនបើ កាលសារវន្តរំពឹងទុកនៃឧបករណ៍មានរយៈពេលតិចជាង ១២ ខែ) ។

រយៈពេលអតិបរមាដែលបានពិចារណានៅពេលធ្វើការប៉ាន់ស្មាន ECL គឺជាអំឡុងពេលអតិបរមានៅក្នុងកិច្ចសន្យា ដែលក្រុមហ៊ុនត្រូវប្រឈមនឹងហានិភ័យហិរញ្ញវត្ថុ ។

*ការវាស់វែង ECL*

ECL គឺជាការប៉ាន់ស្មានភាពអាចកើតមានឡើងជាមធ្យមនៃឥណទានបាត់បង់ ។ ឥណទានបាត់បង់គឺត្រូវ បានវាស់វែងទៅតាមតម្លៃបច្ចុប្បន្ននៃឱនភាពសាច់ប្រាក់ទាំងអស់ (ឧទាហរណ៍ ភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលក្រុមហ៊ុនត្រូវទទួលតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលក្រុមហ៊ុនរំពឹងថានឹងទទួលបាន) ។

ECL ត្រូវបានបញ្ចុះតម្លៃដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ*

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើម ជាឥណទានមានឱនភាពនៃតម្លៃឬទេ ។ ទ្រព្យសកម្មហិរញ្ញវត្ថុក្លាយជា ឥណទានដែលមានឱនភាពនៃតម្លៃ នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនមានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់អនាគតនៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើង ។

ភស្តុតាង ដែលទ្រព្យសកម្មហិរញ្ញវត្ថុមួយជាឥណទានមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេត បានដូចខាងក្រោម ៖

- ផលវិបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អ្នកខ្ចី ឬអ្នកបោះផ្សាយ
- ការធ្វើខុសពីកិច្ចសន្យាដូចជា ការយឺតយ៉ាវ ឬហួសកាលកំណត់សង
- ការរៀបចំឥណទានជាថ្មីរបស់ក្រុមហ៊ុនទៅលើលក្ខខណ្ឌ ដែលក្រុមហ៊ុនមិនធ្វើការពិចារណាពីមុន ឬ
- វាអាចនឹងកើតមានឡើងដែលកូនបំណុលឈានទៅរកក្ស័យធន់ ឬការរៀបចំផ្នែកហិរញ្ញវត្ថុជាថ្មី ។

### ការបង្ហាញអំពីសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

សំវិធានធនការខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងដោយរំលស់ថ្លៃដើម ត្រូវដកចេញពីតម្លៃទ្រព្យសកម្មក្នុងបញ្ជីសរុប ។

### ការលុបចោល

តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺត្រូវបានលុបចោលនៅពេលដែលក្រុមហ៊ុនគ្មានការរំពឹងទុកសមហេតុផលក្នុងការទទួលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុបានទាំងស្រុង ឬមួយផ្នែក ។ សម្រាប់អតិថិជនរូបវន្តបុគ្គល ក្រុមហ៊ុនមានគោលនយោបាយក្នុងការលុបចោលឥណទានដុលដោយផ្អែកលើបទពិសោធន៍នាពេលកន្លងមកក្នុងការទទួលបានមកវិញ នៃទ្រព្យសកម្មដែលមានចរិតលក្ខណៈស្រដៀងគ្នា ។ សម្រាប់អតិថិជនជានីតិបុគ្គល ក្រុមហ៊ុនប៉ាន់ស្មានទ្រព្យសកម្មឯកត្តជននីមួយៗលើការរំពឹងពេលវេលា និងចំនួន ដែលត្រូវលុបចោល ថាតើមានការរំពឹងនូវការប្រមូលបានមកវិញសមហេតុផលឬទេ ។ ក្រុមហ៊ុនរំពឹងថា មិនទទួលបានមកវិញជាសារវន្ត ចំពោះចំនួនដែលលុបចោលនោះទេ ។ ទោះជាយ៉ាងណាក្តី ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលលុបចោលអាចនៅមានវិធានការទាមទារសង ដើម្បីស្របតាមនីតិវិធីរបស់ ក្រុមហ៊ុនសម្រាប់ទារត្រឡប់មកវិញនូវចំនួនដែលមិនទាន់ទទួលបាន ។

### គោលនយោបាយអនុវត្តមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់សញ្ញាណឱនភាពនៃតម្លៃ ។

សញ្ញាណដែលថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមាន ៖

- ការខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងរបស់កូនបំណុល
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណបង្ហាញថាកូនបំណុល នឹងជួបប្រទះការក្ស័យធន
- ការប្រែប្រួលជាអវិជ្ជមានស្ថានភាពទូទាត់របស់កូនបំណុល
- ការបាត់បង់ទីផ្សារសកម្ម សម្រាប់មូលបត្រ ឬ
- ស្ថិតិអង្កេតដែលបង្ហាញថាមាន នឹងមានការថយចុះសាច់ប្រាក់ដែលអាចវាស់វែងបានពីក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ។

### ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម

ក្រុមហ៊ុន ពិចារណារាល់សញ្ញាណនៃឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងលើទ្រព្យសកម្មទោល និងជាក្រុម ។ រាល់ទ្រព្យសកម្មទោលសារវន្ត ត្រូវបានវាយតម្លៃឱនភាពដាច់ដោយឡែក ។ ទ្រព្យសកម្មហិរញ្ញវត្ថុទោលដែលមិនរកឃើញថា មានឱនភាពនៃតម្លៃក្នុងទម្រង់ជាក់លាក់មួយនោះទេ ត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃ ដែលបានកើតឡើងប៉ុន្តែមិនទាន់កំណត់នៅឡើយ ។ គណនីមិនសារវន្តត្រូវបានវាយតម្លៃជាក្រុម ។ ការវាយតម្លៃជាក្រុមត្រូវបានធ្វើឡើង ដោយបញ្ចូលនូវទ្រព្យដែលមានចរិតលក្ខណៈហានិភ័យស្រដៀងគ្នា ។

ក្នុងការវាយតម្លៃឱនភាពនៃតម្លៃជាក្រុម ក្រុមហ៊ុនប្រើប្រាស់ព័ត៌មានពីមុន លើថេរវេលានៃការប្រមូលបាន និងចំនួននៃការខាតបង់កើតឡើង និងធ្វើការវិនិច្ឆ័យលើសេដ្ឋកិច្ចបច្ចុប្បន្ន និងលក្ខខណ្ឌឥណទាន

បច្ចុប្បន្ន ដើម្បីប៉ាន់ស្មានពីការខាតបង់ជាក់ស្តែងអាចច្រើនជាង ឬតិចជាងចំនួនដែលបានកើតឡើង ដោយយោងតាមនិន្នាការពីមុន ។

ការខាតបង់លើឱនភាពនៃតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគណនាដោយផ្អែកលើភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាំអនាគត ដែលធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ។ ការខាតបង់ត្រូវបានទទួលស្គាល់ក្នុង ចំណេញ ឬខាតក្នុងគណនីសំវិធានធន ។ នៅពេលដែល ក្រុមហ៊ុនគិតថា មិនមានសង្ឃឹមក្នុងការទទួលបាននូវការទូទាត់សងចំនួនដែលពាក់ព័ន្ធនឹងត្រូវបានលុបចោល ។ ប្រសិនបើការខាតបង់លើឱនភាពនៃតម្លៃមានការថយចុះនៅពេលបន្ទាប់ហើយការថយចុះអាចពាក់ព័ន្ធនឹងព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីឱនភាពនៃតម្លៃបានទទួលស្គាល់នោះ ការខាតលើឱនភាពនៃតម្លៃដែលបានទទួលស្គាល់ពីមុន ត្រូវបានធ្វើនិយ័តកម្មក្នុងរបាយការណ៍ចំណេញ ឬខាត ។

### (ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនពិនិត្យតម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (លើកលែងតែសន្និធិផ្សេងទៀត) ដើម្បីកំណត់សញ្ញាណនៃឱនភាពនៃតម្លៃ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើងចំនួននៃទ្រព្យសកម្មដែលអាចប្រមូលបានវិញ នឹងត្រូវបានប៉ាន់ស្មាន ។

សម្រាប់ការធ្វើតេស្តឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុម ដែលអាចបង្កើតសាច់ប្រាក់តូចបំផុតពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា (“ឯកតាបង្កើតសាច់ប្រាក់”)។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយការលក់ចេញ ។ តម្លៃប្រើប្រាស់ គឺអាស្រ័យលើការប៉ាន់ស្មាននូវលំហូរសាច់ប្រាក់នាពេលអនាគត អប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាអប្បហារមុនដកពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់ ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់លើសពីចំនួនដែលអាចប្រមូលវិញបាន ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។ ការខាតបង់លើឱនភាព ត្រូវបានបែងចែក ដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មក្នុងឯកតាបង្កើតសាច់ប្រាក់តាមមូលដ្ឋានសមាមាត្រ ។

ការខាតបង់លើឱនភាពនៃតម្លៃ នឹងត្រូវកែសម្រួលត្រឡប់មកវិញត្រឹមកម្រិតមួយ ដែលធ្វើឲ្យតម្លៃយោងនៃទ្រព្យសកម្ម មិនលើសពីតម្លៃយោងនៃទ្រព្យសកម្មក្រោយដករំលស់ ប្រសិនបើមិនមានការខាតបង់លើឱនភាពនៃតម្លៃ ។

## (ឆ) ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន តាមចំនួនដែលតម្រូវដោយគណៈកម្មការមូលបត្រកម្ពុជា ដែលបានកំណត់ នៅក្នុងមាត្រា ១៧ នៃប្រកាសលេខ ០០៩/គ.ម.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩

ស្តីអំពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដែលចេញដោយគណៈកម្មការមូលបត្រកម្ពុជា ។

ប្រាក់បញ្ញើតម្កល់ ត្រូវបានកត់ត្រាតាមតម្លៃដើម ។

### (ជ) សំវិធានធនលើអត្ថប្រយោជន៍និយោជិត

#### (i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានចាត់ទុកជាចំណាយ នៅពេលនិយោជិតផ្តល់សេវាកម្មពាក់ព័ន្ធ ។ បំណុលត្រូវបានទទួលស្គាល់លើចំនួនដែលរំពឹងថានឹងត្រូវទូទាត់ ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬប្រយោលក្នុងការទូទាត់ចំនួននេះ ដែលជាលទ្ធផលនៃសេវាកម្មដែលបានផ្តល់រួចដោយនិយោជិត ហើយកាតព្វកិច្ចទូទាត់អាចប៉ាន់ស្មានដោយភាពជាក់លាក់ ។

#### (ii) មូលនិធិសោធននិវត្តន៍បុគ្គលិក

មកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុនផ្តល់ជូនបុគ្គលិករបស់ខ្លួននូវមូលនិធិសោធននិវត្តន៍ដែលជាគម្រោងកំណត់វិភាគទាន ។ មូលនិធិនេះ គឺបានពីវិភាគទានប្រចាំខែដែលត្រូវបានកំណត់ដោយអាស្រ័យទៅតាមប្រាក់បៀវត្សប្រចាំខែរបស់បុគ្គលិក ។ ក្រុមហ៊ុនផ្តល់វិភាគទានចំនួន ១០% ហើយបុគ្គលិកផ្តល់វិភាគទាន ចំនួន ៥% នៃប្រាក់បៀវត្ស ។

មូលនិធិនេះ ត្រូវបានរក្សាទុកដោយក្រុមហ៊ុនមេ ។ វិភាគទានរបស់ក្រុមហ៊ុនត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងចំណេញ ឬខាត នៅក្នុងឆ្នាំហិរញ្ញវត្ថុដែលពាក់ព័ន្ធ ។ នៅពេលដែលវិភាគទានត្រូវបានបង់ទៅឲ្យក្រុមហ៊ុនមេរួច ក្រុមហ៊ុនមិនមានកាតព្វកិច្ចទូទាត់នាពេលអនាគតទៀតទេ ។

ក្រុមហ៊ុនមេនឹងទូទាត់មូលនិធិសោធននិវត្តន៍ទាំងស្រុងជូនបុគ្គលិក នៅពេលដែលពួកគេលាឈប់ពីការងារក្រុមហ៊ុន ។ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ ក្រុមហ៊ុនបានកែប្រែគោលការណ៍ ហើយបានសម្រេចឈប់ផ្តល់មូលនិធិសោធននិវត្តន៍នេះ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ ។

#### (iii) អត្ថប្រយោជន៍ពេលចូលនិវត្ត

ក្រុមហ៊ុន ផ្តល់ជូនបុគ្គលិកពេញសិទ្ធិរបស់ខ្លួននូវគម្រោងអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលមិនមានមូលនិធិដាច់ដោយឡែក នៅពេលដែលពួកគាត់ដល់អាយុចូលនិវត្ត ដូចខាងក្រោម ៖

- បុគ្គលិកដែលមានអតីតភាពការងារជាមួយក្រុមហ៊ុនចំនួន ១៥ ឆ្នាំ ឬលើស ហើយត្រូវដល់អាយុចូលនិវត្តនៅអាយុ ៥៨ ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៦០ ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងត្រូវទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សចំនួន ១២ ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយ ។
- បុគ្គលិកដែលមានអតីតភាពការងារជាមួយក្រុមហ៊ុនចំនួន ១៥ ឆ្នាំ ឬលើស ហើយត្រូវដល់អាយុចូលនិវត្តមុនអាយុ ៥៥ ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៥៧ ឆ្នាំចំពោះអ្នកមានជំនាញ នឹងត្រូវទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សចំនួន ៦ ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយ ។

ចំពោះអត្ថប្រយោជន៍ពេលចូលនិវត្តនេះ មិនមានរក្សាទុកក្នុងមូលនិធិដាច់ដោយឡែកទេ ហើយក៏មិនមានការប្រាក់ដែរ ។

បំណុលត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់ នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រឯកតាឥណទានប៉ាន់ស្មាន ដើម្បីប៉ាន់ប្រមាណនូវថ្លៃចំណាយចុងក្រោយបំផុត ដែលក្រុមហ៊ុនចំណាយចំពោះអត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបាន ជាថ្នូរនឹងការបម្រើការងាររបស់ពួកគេ ក្នុងពេលបច្ចុប្បន្ន និងពេលកន្លងមក ។ ក្រុមហ៊ុនចូលរួមផ្តល់វិភាគទានក្នុងរយៈពេលដែលមានការទូទាត់អត្ថប្រយោជន៍ពេលចូលនិវត្ត ។ កាតព្វកិច្ចនោះកើតឡើងនៅពេលដែលបុគ្គលិកបម្រើការងារដើម្បីទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលក្រុមហ៊ុនរំពឹងថានឹងទូទាត់ក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត ។

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត ត្រូវបានកំណត់ដោយអប្បហារចំណាយត្រូវបង់ប៉ាន់ស្មាន នាពេលអនាគត ដោយយោងទៅតាមអត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៦ ឆ្នាំ របស់ធនាគារ ។

ចំណេញ និង ខាត ដែលកើតពីនិយ័តកម្មក្នុងគ្រាកន្លងមក និងពីបម្រែបម្រួលការសន្មតហានិភ័យត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងការិយបរិច្ឆេទដែលមានប្រតិបត្តិការនោះកើតឡើង ។ ចំណាយទាក់ទិននឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ ឬខាត ដើម្បីបែងចែកចំណាយទាំងនោះ លើរយៈពេលដែលបុគ្គលិកបម្រើការងារ ហើយមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ ។ ចំណាយលើការបម្រើការងារក្នុងអតីតកាលត្រូវបានកត់ត្រាភ្លាមៗនៅក្នុងរបាយការណ៍ចំណេញ ឬខាត ។

### (iv) ប្រាក់បំណាច់អតីតភាពការងារ

យោងទៅតាមប្រកាសលេខ ៩៤៣ ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុននឹងផ្តល់ជូននិយោជិត នូវប្រាក់បំណាច់អតីតភាពការងារដូចខាងក្រោម ៖

- ប្រាក់បំណាច់អតីតភាពការងារបច្ចុប្បន្ន ៖ និយោជិតដែលបម្រើការចាប់ពី ១ ខែ ដល់ ៦ ខែ(មិនរាប់បញ្ចូលរយៈពេលសាកល្បងការងារ) គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឬថ្ងៃទី៣១ ខែធ្នូ នឹងទទួលបានប្រាក់បំណាច់អតីតភាពការងារចំនួន ៧.៥ ថ្ងៃ ។
- ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ៖ និយោជិតដែលបម្រើការក្រោមកិច្ចសន្យាមានថេរវេលាមិនកំណត់ ហើយបម្រើការចាប់ពី ១ ខែ ដល់ ៦ ខែ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ និងទទួលបានប្រាក់ បំណាច់អតីតភាពការងារស្មើនឹង ៧.៥ ថ្ងៃ ហើយក្នុងករណីបម្រើការលើសពី ៦ ខែ នឹងទទួលបាន ១៥ ថ្ងៃ ។ ប្រាក់បំណាច់អតិបរមា មិនត្រូវលើសពី ៦ ខែ នៃប្រាក់ឈ្នួលសុទ្ធសាធ គិតជាមធ្យមតាមឆ្នាំនីមួយៗ ដែលបានបង់ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ប៉ុន្តែមិនត្រូវលើសពី ១៥៦ ថ្ងៃឡើយ ។

បំណុលប្រាក់បំណាច់នេះ ត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចត្រូវទូទាត់នាកាលបរិច្ឆេទរាយការណ៍ដោយប្រើវិធីសាស្ត្រឯកតាឥណទានប៉ាន់ស្មាន ដើម្បីប៉ាន់ស្មានចំណាយចុងក្រោយដែលអាចនឹងត្រូវទូទាត់ដោយក្រុមហ៊ុនលើប្រាក់បំណាច់អតីតភាពការងារ ដែលនិយោជិតមានសិទ្ធិទទួលលើការបម្រើការងារចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ។ ក្រុមហ៊ុនបែងចែកប្រាក់បំណាច់អតីតភាពការងារទៅតាមថេរវេលា ដែលត្រូវទូទាត់ប្រាក់បំណាច់នេះ ។ កាតព្វកិច្ចបំណុលកើតឡើងនៅពេល

និយោជិតបម្រើការងារ ដើម្បីទទួលបាននូវប្រាក់បំណាច់អតីតភាពការងារ ដែលក្រុមហ៊ុនរំពឹងថានឹងត្រូវទូទាត់នៅកាលបរិច្ឆេទរាយការណ៍អនាគត ។

តម្លៃបច្ចុប្បន្នប្រាក់បំណាច់អតីតភាពការងារ ត្រូវបានកំណត់ដោយធ្វើអប្បហារប្រាក់ដែលត្រូវទូទាត់ពេលអនាគត ហើយប្រើអត្រាការប្រាក់កម្ចីមានកាលកំណត់ចំនួន ៦ឆ្នាំ ។

### (ឈ) សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ចប្រយោលដែលកើតពីលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ដែលទំនងជាតម្រូវឲ្យក្រុមហ៊ុនចំណាយធនធាន ដើម្បីធ្វើការដោះស្រាយ និងទូទាត់កាតព្វកិច្ចទាំងនោះ ហើយចំនួនទឹកប្រាក់នោះអាចប៉ាន់ស្មានគួរឲ្យជឿជាក់បាន ។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល ។ សំវិធានធនត្រូវបានកត់ត្រាទោះបីជាលំហូរចេញនៃធាតុណាមួយដែលស្ថិតនៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចតែមួយនោះ មានចំនួនតិចតួចក៏ដោយ ។

សំវិធានធនត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ន នៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់ ។

### (ញ) ប្រាក់ចំណូល

ចំណូល ត្រូវបានវាស់វែងផ្អែកលើតម្លៃតបស្នងដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាអតិថិជន ។ ក្រុមហ៊ុនទទួលស្គាល់ចំណូលនៅពេលផ្ទេរការគ្រប់គ្រងទំនិញ និងសេវាកម្មឲ្យអតិថិជន ។

*សភាព និងពេលវេលានៃការបំពេញកាតព្វកិច្ចរួមទាំងលក្ខខណ្ឌទូទាត់សំខាន់ៗ*

ក្រុមហ៊ុនផ្តល់សេវាជាឈ្មួញជើងសាមូលបត្រទៅឲ្យអតិថិជនរបស់ខ្លួន ។ ថ្លៃសេវាត្រូវបានទទួលស្គាល់ជាទូទៅនៅពេលសេវាកម្មត្រូវបានផ្តល់ឲ្យទាំងស្រុង ។ ការទូទាត់គួរត្រូវបានធ្វើឡើងក្នុងរយៈពេល ២ ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ (T+២) ពីកាលបរិច្ឆេទជួញដូរ ។

*ការទទួលស្គាល់ប្រាក់ចំណូលតាម ស.រ.ហ.អ.ក ១៥ (អនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨)*

ប្រាក់ចំណូល ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានបំពេញ និងត្រូវបានទទួលស្គាល់ដោយអតិថិជនថាបានបញ្ចប់ ។

*ការទទួលស្គាល់ប្រាក់ចំណូលក្រោម ស.គ.អ.ក ១៨ (អនុវត្តមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨)*

ប្រាក់ចំណូលត្រូវបានវាស់វែងតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ឬត្រូវទទួល ហើយវាគឺជាចំនួនទឹកប្រាក់ដែលត្រូវទទួលពីសេវាដែលក្រុមហ៊ុនបានបំពេញជូនអតិថិជន និងត្រូវបានរាយការណ៍តាមតម្លៃសុទ្ធ ដកអប្បហារ និងអាករលើតម្លៃបន្ថែម ។ ក្រុមហ៊ុនទទួលស្គាល់ប្រាក់ចំណូលនៅពេល

ដែលចំនួនទឹកប្រាក់ចំណូលនោះ អាចវាស់វែងគួរឲ្យជឿជាក់បាន និងនៅពេលដែលភាពប្រាកដថាមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនឹងហូរចូលមកក្នុងក្រុមហ៊ុន និងនៅពេលលក្ខណៈវិនិច្ឆ័យជាក់លាក់ ត្រូវបានបំពេញទៅតាមសកម្មភាពអាជីវកម្មនីមួយៗរបស់ក្រុមហ៊ុន ដូចបានរៀបរាប់ខាងក្រោម ។

### (ដ) ចំណូលហិរញ្ញវត្ថុ

ចំណូលហិរញ្ញវត្ថុ រួមមានចំណូលការប្រាក់ ។ ចំណូលការប្រាក់ ត្រូវទទួលស្គាល់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

### (ឋ) ការទូទាត់ភតិសន្យា

ការទូទាត់ក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតក្នុងរបាយការណ៍លទ្ធផល តាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ការលើកទឹកចិត្តភតិសន្យាដែលទទួលបាន ត្រូវបានទទួលស្គាល់ជាផ្នែកនៃចំណាយភតិសន្យាតាមថេរវេលានៃភតិសន្យា ។

### (ទ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ វាត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែធាតុណាបានទទួលស្គាល់ដោយផ្ទាល់ ក្នុងមូលធន ឬនៅក្នុងរបាយការណ៍លម្អិតផ្សេងៗទៀត ។

*ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរបាយការណ៍ជាមួយនឹងនិយ័តភាពណាមួយ លើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

*ពន្ធពន្យារ*

ពន្ធពន្យារ ត្រូវបានកំណត់ទៅលើភាពលម្អៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ការខាតលើពន្ធ និងភាពលម្អៀងជាបណ្តោះអាសន្ន ដែលអាចកាត់កងបាន តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់បាន ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរបាយការណ៍ ហើយត្រូវបានកាត់បន្ថយ ក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន ។ ការកាត់បន្ថយនេះនឹងត្រូវប្តូរត្រឡប់វិញនៅពេលដែលលក្ខខណ្ឌនៃប្រាក់ចំណេញ ជាប់ពន្ធនាពេលអនាគតមានភាពប្រសើរវិញ ។

ពន្ធពន្យារ ត្រូវបានកំណត់ដោយប្រើអត្រាពន្ធដែលរំពឹងថានឹងប្រើទៅលើភាពលម្អៀងជាបណ្តោះអាសន្ន ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរបាយការណ៍ ។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងពីលទ្ធផលដែលក្រុមហ៊ុនរំពឹងថា (នៅកាលបរិច្ឆេទរាយការណ៍) នឹងមានទទួលមកវិញ ឬការកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ។

ពន្ធពន្យារ ទ្រព្យសកម្មនិងបំណុលអាចកាត់កងគ្នាបានលុះត្រាតែបានបំពេញលក្ខខណ្ឌមួយចំនួន ។

## ៤. ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យសំខាន់ៗ

ក្រុមហ៊ុន បានអនុវត្តដំបូងនូវស្តង់ដារ ស.រ.ហ.អ.ក ១៥ *ចំណូលពីកិច្ចសន្យាអតិថិជន* និង ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ* ប៉ុន្តែវាមិនមានផលប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ ។

ដោយសារតែវិធីសាស្ត្រអន្តរកាលដែលក្រុមហ៊ុនជ្រើសរើស ក្នុងការអនុវត្តស្តង់ដារថ្មី ការកែប្រែ និងការបកស្រាយថ្មីៗ ព័ត៌មានប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មិនត្រូវបានកែប្រែដើម្បីសម្របទៅតាមតម្រូវការស្តង់ដារថ្មីឡើយ ។

### (ក) ស.រ.ហ.អ.ក ១៥ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន*

ស.រ.ហ.អ.ក ១៥ បង្កើតក្របខណ្ឌដ៏ទូលំទូលាយមួយសម្រាប់កំណត់ថាតើ ចំណូលប៉ុន្មាន និងពេលណាចំណូល ត្រូវបានទទួលស្គាល់ ។ វាជំនួស ស.គ.អ.ក ១៨ *ចំណូល* ស.គ.អ.ក ១១ *កិច្ចសន្យាសាងសង់ និងការបកស្រាយពាក់ព័ន្ធ* ។ នៅក្រោម ស.រ.ហ.អ.ក ១៥ ប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅពេលអតិថិជនទទួលបានការត្រួតពិនិត្យលើទំនិញ និងសេវាកម្ម ។ កំណត់ពេលវេលានៃការផ្ទេរការគ្រប់គ្រងនៅពេលវេលាតែមួយ ឬក្នុងអំឡុងពេលមួយ តម្រូវឲ្យមានការវិនិច្ឆ័យ ។

ក្រុមហ៊ុនបានអនុវត្ត ស.រ.ហ.អ.ក ១៥ ដោយប្រើវិធីសាស្ត្រផលប៉ះពាល់បង្គរនៃការអនុវត្តស្តង់ដារដំបូងគឺថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ។ ដូច្នោះហើយ ព័ត៌មានដែលបានបង្ហាញសម្រាប់ឆ្នាំ២០១៧ មិនត្រូវបានបង្ហាញឡើងវិញទេ ពោលគឺវាត្រូវបានបង្ហាញ ដូចដែលបានរាយការណ៍ពីមុនក្រោម ស.គ.អ.ក ១៨ ស.គ.អ.ក ១១ និងការបកស្រាយពាក់ព័ន្ធ ។ លើសពីនេះ តម្រូវការបង្ហាញក្នុង ស.រ.ហ.អ.ក ១៥ មិនត្រូវបានអនុវត្តជាទូទៅនោះទេចំពោះព័ត៌មានប្រៀបធៀប ។

ក្រុមហ៊ុនបានធ្វើការវាយតម្លៃលើផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក ១៥ ហើយបានសន្និដ្ឋានថាប្រាក់ចំណូល លើការទិញ-លក់មូលបត្រ ឈ្នួញជើងសា និងសេវាទាក់ទងនឹងមូលបត្រ ត្រូវបានទទួលស្គាល់ក្នុងពេលតែមួយ នៅពេលសេវាកម្មត្រូវបានផ្តល់ ដែលដូចគ្នានឹង ស.គ.អ.ក ១៨ ។ ដូច្នោះហើយ ការអនុវត្តនៃ ស.រ.ហ.អ.ក ១៥ មិនមានផលប៉ះពាល់ ផ្នែកហិរញ្ញវត្ថុជាសារវន្តទៅលើពេលវេលា និងប្រាក់ចំណូលដែលត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទមុន និងការិយបរិច្ឆេទបច្ចុប្បន្ននោះទេ ។

### (ខ) ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ*

ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ* កំណត់ពីតម្រូវការក្នុងការទទួលស្គាល់ និងការវាស់វែង នូវទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាខ្លះដែលពាក់ព័ន្ធនឹងការទិញ-លក់វត្ថុដែលមិនមែនហិរញ្ញវត្ថុ ។ ស្តង់ដារនេះបានជំនួស ស.គ.អ.ក ៣៩ *ឧបករណ៍ហិរញ្ញវត្ថុ ការទទួលស្គាល់ និងការវាស់វែង* ។

ជាលទ្ធផលនៃការអនុវត្ត ស.រ.ហ.អ.ក ៩ ក្រុមហ៊ុនបានអនុវត្តតាមវិសោធនកម្មសមស្របទៅលើ ស.គ.អ.ក ១ *ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ* ដែលតម្រូវឱ្យបង្ហាញឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងធាតុដាច់ដោយឡែកមួយនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងទៀត ។ ការអនុវត្តស្តង់ដារនេះ មិនមានផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុទេ ដោយសារក្រុមហ៊ុនមិនមានឱនភាពនៃតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ ។

លើសពីនេះទៀត ក្រុមហ៊ុនបានអនុវត្តតាមវិសោធនកម្ម ស.រ.ហ.អ.ក ៧ ស្តី*ពីការលាតត្រដាងព័ត៌មានឧបករណ៍ហិរញ្ញវត្ថុ* អំពីឆ្នាំ២០១៨ ប៉ុន្តែមិនត្រូវបានអនុវត្តជាទូទៅសម្រាប់ព័ត៌មានប្រៀបធៀបនោះឡើយ ។

### *(i) ធ្វើចំណាត់ថ្នាក់ និងការវាស់វែងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ*

ស.រ.ហ.អ.ក ៩ រួមមាន ចំណាត់ថ្នាក់ចម្បងៗ ចំនួន ៣ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ៖ វាស់វែងតាមរំលស់ថ្លៃដើម, FVOCI និង FVTPL ។ ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុតាម ស.រ.ហ.អ.ក ៩ ជាទូទៅផ្អែកលើ គំរូអាជីវកម្មដែលគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងចរិតលក្ខណៈនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យា ។ ស្តង់ដារនេះ លុបចោលនូវចំណាត់ថ្នាក់ដែលមានស្រាប់ក្នុង ស.គ.អ.ក ៣៩ ដែលរួមមានចំណាត់ថ្នាក់ កាន់កាប់រហូតដល់កាលកំណត់ឥណទាន និងគណនីត្រូវទទួល និងសម្រាប់លក់ ។

ស.រ.ហ.អ.ក ៩ ភាគច្រើនរក្សាតម្រូវការដែលមានស្រាប់នៅក្នុង ស.គ.អ.ក ៣៩ សម្រាប់ការធ្វើចំណាត់ថ្នាក់ និងការវាស់វែងបំណុលហិរញ្ញវត្ថុ ។

ការអនុវត្ត ស.រ.ហ.អ.ក ៩ មិនមានផលប៉ះពាល់ជាសារវន្តលើគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុ ។ សម្រាប់ការពន្យល់អំពីរបៀបដែលក្រុមហ៊ុនបានធ្វើចំណាត់ថ្នាក់ និង វាស់វែងឧបករណ៍ហិរញ្ញវត្ថុ និងកត់ត្រាការចំណេញ ឬខាតនៅក្រោម ស.រ.ហ.អ.ក. ៩ សូមមើលកំណត់សម្គាល់ ៣ (ខ) ។

តារាង និងកំណត់សម្គាល់ដែលបានរៀបរាប់ខាងក្រោមពន្យល់ពីការវាស់វែងដំបូងនៅក្នុង ស.គ.អ.ក ៣៩ និងការវាស់វែងថ្មីនៅក្រោម ស.រ.ហ.អ.ក ៩ សម្រាប់ប្រភេទនីមួយៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ។

| | ចំណាត់ថ្នាក់ដើម ស្តង់ដារ ស.គ.អ.ក ៣៩ | ចំណាត់ថ្នាក់ថ្មី ស្តង់ដារស.រ.ហ.អ.ក ៩ | តម្លៃដើម/ តម្លៃយោងថ្មី ដុល្លារអាមេរិក |
|---|---|---|---|
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | |
| សាច់ប្រាក់និងសាច់ប្រាក់សមមូល | ឥណទាន និងគណនីត្រូវទទួល | រំលស់ថ្លៃដើម | ៦៩.៤៧៩ |
| ប្រាក់បញ្ញើមានកាលកំណត់ | ឥណទាន និងគណនីត្រូវទទួល | រំលស់ថ្លៃដើម | ១.៩២៤.៤៣៩ |
| ទ្រព្យសកម្មផ្សេងៗ | ឥណទាន និងគណនីត្រូវទទួល | រំលស់ថ្លៃដើម | ៣៥.២៣៤ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | | | **២.០២៩.១៥២** |
| **បំណុលហិរញ្ញវត្ថុ** | | | |
| ប្រាក់បង្គរនិងគណនីត្រូវទូទាត់ផ្សេងៗ | បំណុលហិរញ្ញវត្ថុផ្សេងៗ | បំណុលហិរញ្ញវត្ថុផ្សេងៗ | ៤៩.៧៧៩ |
| **បំណុលហិរញ្ញវត្ថុសរុប** | | | **៤៩.៧៧៩** |

*(ii) ឱនភាពនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ស.រ.ហ.អ.ក ៩ ជំនួសទម្រង់ "ការខាតបង់ដែលបានកើតឡើង"នៅក្នុង ស.គ.អ.ក ៣៩ ដោយទម្រង់នៃការប្រមើលមើលទៅអនាគតនៃ "ឥណទានដែលរំពឹងថានឹងបាត់បង់" ។ ទម្រង់ឱនភាពនៃតម្លៃថ្មី នឹងអនុវត្តលើទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងដោយរំលស់តម្លៃដើម ឬតម្លៃសមស្របដោយភាពលម្អៀងត្រូវបានបញ្ចូលទៅក្នុងលទ្ធផលលម្អិតផ្សេងៗ លើកលែងតែការវិនិយោគក្នុងឧបករណ៍មូលធន ។ ស.រ.ហ.អ.ក ៩ ឥណទានបាត់បង់ ត្រូវបានទទួលស្គាល់នៅ ស.គ.អ.ក ៣៩ (មើលក្នុងកំណត់សម្គាល់ ៣ (ច) ។

ការអនុវត្តស្តង់ដារ ស.រ.ហ.អ.ក មិនធ្វើឲ្យមានសំវិធានធនបន្ថែម សម្រាប់ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ឡើយ ។

## ៥. ស្តង់ដារថ្មី ការកែប្រែ និងការបកស្រាយថ្មីដែលមិនទាន់បានអនុម័ត

ស្តង់ដារថ្មី ការកែប្រែ និងការបកស្រាយថ្មីមួយចំនួន ទាក់ទងនឹងស្តង់ដារដែលមានស្រាប់ បានចូលជាធរមាន សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដែលការអនុវត្តមុនកាលកំណត់ត្រូវបានអនុញ្ញាត ។ យ៉ាងណាមិញ ក្រុមហ៊ុនមិនទាន់បានអនុវត្តនូវស្តង់ដារថ្មី ឬស្តង់ដារដែលបានកែប្រែទាំងនេះ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះនៅឡើយទេ ។

(ក) ស.រ.ហ.អ.ក ១៦ *ភតិសន្យា*

ក្រុមហ៊ុន តម្រូវឲ្យអនុវត្ត ស.រ.ហ.អ.ក ១៦ *ភតិសន្យា* ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ។ ក្រុមហ៊ុន បានធ្វើការវាយតម្លៃពីផលប៉ះពាល់ដែលស្តង់ដារ ស.រ.ហ.អ.ក ១៦ មានដល់របាយការណ៍ហិរញ្ញវត្ថុដូចរៀបរាប់ខាងក្រោម ។ ផលប៉ះពាល់ជាក់ស្តែងនៃការអនុវត្តស្តង់ដារ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ អាចនឹងផ្លាស់ប្តូរដោយសារតែគោលនយោបាយគណនេយ្យថ្មីមានការផ្លាស់ប្តូររហូតដល់ ក្រុមហ៊ុនបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមបញ្ចូលកាលបរិច្ឆេទអនុវត្តស្តង់ដារដំបូង ។

ស.រ.ហ.អ.ក ១៦ ណែនាំគំរូគណនេយ្យជួលតាមតារាងតុល្យការតែមួយសម្រាប់អ្នកជួល ។ អ្នកជួលទទួលស្គាល់ទ្រព្យសម្បត្តិ ដែលតំណាងឲ្យសិទ្ធិរបស់ខ្លួនក្នុងការប្រើទ្រព្យសម្បត្តិមូលដ្ឋាន និងបំណុលជួល ដែលតំណាងឲ្យកាតព្វកិច្ចរបស់ខ្លួនក្នុងការធ្វើការចំណាយជួល ។ មានការលើកលែងការទទួលស្គាល់ សម្រាប់ការជួលរយៈពេលខ្លី និងការជួលរបស់របរដែលមានតម្លៃទាប ។ ការកត់ត្រារបស់អ្នកជួលនៅតែស្រដៀងនឹងស្តង់ដារបច្ចុប្បន្ន ឧទាហរណ៍អ្នកជួលបន្តចាត់ថ្នាក់ភតិសន្យាជា ភតិសន្យាហិរញ្ញវត្ថុ ឬប្រតិបត្តិការជួល ។

ស.រ.ហ.អ.ក ១៦ ជំនួសឲ្យការណែនាំដែលមានស្រាប់លើភតិសន្យា ដោយរួមបញ្ចូល ស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") ១៧ *ភតិសន្យា* និង គណៈកម្មការបកស្រាយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("គ.ប.រ.ហ.អ") ៤ *លើការកំណត់សមាសភាពនៃកិច្ចព្រមព្រៀង និង*

*គណៈកម្មការបកស្រាយស្តង់ដារ* (គ.ប.ស) ១៥ *លើភតិសន្យាប្រតិបត្តិការ ស្តីពីការលើកទឹកចិត្ត* និង គ.ប.ស ២៧ *លើការវាយតម្លៃលើខ្លឹមសាររបស់ប្រតិបត្តិការដែលទាក់ទងទៅនឹងទម្រង់គតិយុត្តិរបស់ភតិសន្យា* ។

(i) ភតិសន្យាដែលក្រុមហ៊ុនជាភតិក:

ក្រុមហ៊ុននឹងទទួលស្គាល់នូវទ្រព្យសកម្ម និងបំណុលថ្មីសម្រាប់ជួលប្រតិបត្តិការការិយាល័យ ។ លក្ខណៈនៃការចំណាយទាក់ទងទៅនឹងភតិសន្យា ទាំងនោះនឹងផ្លាស់ប្តូរដោយសារតែក្រុមហ៊ុននឹងទទួលខុសត្រូវលើរំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិ និងចំណាយការប្រាក់លើបំណុលភតិសន្យា ។

មុនក្រុមហ៊ុនកត់ត្រាការចំណាយភតិសន្យាប្រតិបត្តិការត្រូវបានធ្វើឡើង តាមមូលដ្ឋានរំលស់ថេរតាមរយៈពេលនៃការជួល និងទទួលស្គាល់ជាទ្រព្យសកម្ម និងបំណុលតែក្នុងកម្រិតដែលមានភាពខុសគ្នារវាង ការទូទាត់ភតិសន្យាជាក់ស្តែង និងចំណាយដែលត្រូវបានទទួលស្គាល់ ។

ដោយផ្អែកលើការធ្វើការវាយតម្លៃដំបូង ក្រុមហ៊ុនមិនរំពឹងថា ស.រ.ហ.អ.ក ១៦ ភតិសន្យានឹងមានផលប៉ះពាល់ខ្លាំងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ។

(ii) អន្តរកាល

ក្រុមហ៊ុនមានគម្រោងអនុវត្ត ស.រ.ហ.អ.ក ១៦ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដោយប្រើវិធីសាស្រ្តកំណែប្រតិសកម្ម ។ ដូច្នេះ ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក ១៦ នឹងត្រូវបានទទួលស្គាល់ថាជាការកែតម្រូវប្រាក់ចំណេញរក្សាទុកនាដើមការិយបរិច្ឆេទនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដោយគ្មានការកែតម្រូវព័ត៌មានប្រៀបធៀបឡើយ ។

ក្រុមហ៊ុនមានគម្រោងអនុវត្តតាមវិធីសាស្រ្តអនុវត្តជាក់ស្តែងនៃនិយមន័យប្រភពដើមដំបូង (grandfather) នៃការជួលលើការផ្លាស់ប្តូរនេះ ។ នេះមានន័យថាវានឹងអនុវត្ត ស.រ.ហ.អ.ក ១៦ លើកិច្ចសន្យាទាំងអស់ដែលបានចូលជាធរមានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ និងកិច្ចសន្យាដែលបានចាត់ទុកថាជួលស្របតាម ស.គ.អ.ក ១៧ និង គ.ប.រ.ហ.អ ៤ ។

(ខ) ស្តង់ដារគណនេយ្យផ្សេងៗទៀត

ស្តង់ដារដែលមានការកែប្រែ និងបកស្រាយមួយចំនួនខាងក្រោមនឹងមិនមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ ។

- ការបកស្រាយ គ.ប.រ.ហ.អ .២៣ ភាពមិនច្បាស់លាស់លើការកត់ត្រាពន្ធលើប្រាក់ចំណេញ ។
- ការទូទាត់មុនជាមួយសំណងអវិជ្ជមាន (វិសោធនកម្មលើ ស.រ.ហ.អ.ក ៩)
- ការប្រាក់រយៈពេលវែងក្នុងសម្ព័ន្ធ និងក្រុមហ៊ុនរួម (វិសោធនកម្មលើ ស.គ.អ.ក ២៨)
- ផែនការកែប្រែវិសោធនកម្ម ឬការទូទាត់ (វិសោធកម្មលើ ស.គ.អ.ក ១៩)

- ការកែលម្អប្រចាំឆ្នាំទៅលើ ស្តង់ដារ ស.រ.ហ.អ.ក ២០១៥ ដល់ ២០១៧ ស្តង់ដាគណនេយ្យផ្សេងៗ
- វិសោធនកម្មសេចក្តីយោងទៅក្របខណ្ឌគោលគំនិតក្នុងស្តង់ដារ ស.រ.ហ.អ.ក
- ស.រ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រង ។

## ៦. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីបំពេញតាមតម្រូវការដែលមានចែងនៅក្នុងច្បាប់គណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

ទ្រព្យសកម្ម និងបំណុល ត្រូវបានប្តូររូបិយប័ណ្ណតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ។ របាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានបង្ហាញជាប្រាក់រៀលដោយប្រើប្រាស់អត្រាមធ្យមភាគប្រចាំឆ្នាំ ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណនេះ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ។

ក្រុមហ៊ុន ប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម៖

| | អត្រានាចុងកាលបរិច្ឆេទ | |
|---|---|---|
| | រាយការណ៍ | អត្រាមធ្យម |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ១ដុល្លារអាមេរិក = | ៤.០១៨ រៀល | ៤.០៤៥ រៀល |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ១ដុល្លារអាមេរិក = | ៤.០៣៧ រៀល | ៤.០៤៥ រៀល |

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

## ៧. ប្រាក់បញ្ញើតម្កល់តាមច្បាប់

អនុលោមតាមប្រកាសរបស់ គ.ម.ក. លេខ ០០៩ ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនត្រូវបានតម្រូវឲ្យដាក់ប្រាក់តម្កល់ (យ៉ាងហោចណាស់ ១ ពាន់លានរៀល) ទៅក្នុងគណនីរបស់ គ.ម.ក. ដែលរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការជាឈ្មួញជើងសារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រាក់តម្កល់ (មិនមានការប្រាក់) នេះមិនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការ ប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ រហូតដល់ពេលដែលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នៅព្រះរាជាណាចក្រកម្ពុជា ។

## ៨. ទ្រព្យសកម្មអរូបី

| ២០១៨ | កម្មវិធីកំព្យូទ័រ | អាជ្ញាប័ណ្ណ គ.ម.ក | សរុប | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ | ១.៥៧៤ | ១៥.៤៣១ | ១៧.០០៥ | ៦៨.៦៩៩ |
| ការទិញបន្ថែម | - | ១៥.៤៤១ | ១៥.៤៤១ | ៦២.៤៥៩ |
| ការលុបចោល | - | (១៥.៤៣១) | (១៥.៤៣១) | (៦២.៤១៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (៣២៤) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ១.៥៧៤ | ១៥.៤៤១ | ១៧.០១៥ | ៦៨.៣៦៦ |
| ដក: **រំលស់បង្គរ** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ | ១.៥៧៤ | ១០.៦១៩ | ១២.១៩៣ | ៤៩.២២៣ |
| រំលស់ក្នុងការិយបរិច្ឆេទ | - | ៤.៨១២ | ៤.៨១២ | ១៩.៤៦៥ |
| ការលុបចោល | | (១៥.៤៣១) | (១៥.៤៣១) | (៦២.៤១៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ៥៤ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ១.៥៧៤ | - | ១.៥៧៤ | ៦.៣២៤ |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | - | ១៥.៤៤១ | ១៥.៤៤១ | ៦២.០៤២ |
| **២០១៧** | | | | |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧/ ៣១ ខែធ្នូ ឆ្នាំ២០១៧ | ១.៥៧៤ | ១៥.៤៣១ | ១៧.០០៥ | ៦៨.៦៩៩ |
| ដក: **រំលស់បង្គរ** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ១.៤០៥ | ៤.៨៤៣ | ៦.២៤៨ | ២៥.២២៣ |
| រំលស់ក្នុងការិយបរិច្ឆេទ | ១៦៩ | ៥.៧៧៦ | ៥.៩៤៥ | ២៤.០៤៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (៤៨) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ១.៥៧៤ | ១០.៦១៩ | ១២.១៩៣ | ៤៩.២២៣ |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | - | ៤.៨១២ | ៤.៨១២ | ១៩.៤២៦ |

# ៩. ទ្រព្យ និង បរិក្ខារ

| ២០១៨ | សម្ភារការិយាល័យ ដុល្លារអាមេរិក | សម្ភារកុំព្យូទ័រ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់ ៦) |
|---|---|---|---|---|
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ | ៧.៦៧៩ | ៤៧.៥២៧ | ៥៥.២០៦ | ២២២.៨៦៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (១.០៤៩) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ៧.៦៧៩ | ៤៧.៥២៧ | ៥៥.២០៦ | ២២១.៨១៨ |
| ដក: **រំលស់បង្គរ** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ | ៧.៣០៩ | ៤៤.៩៥២ | ៥២.២៦១ | ២១០.៩៧៨ |
| រំលស់ក្នុងការិយបរិច្ឆេទ | ៣៧០ | ១.១៩០ | ១.៥៦០ | ៦.៣១០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (១.០៣៥) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ៧.៦៧៩ | ៤៦.១៤២ | ៥៣.៨២១ | ២១៦.២៥៣ |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | - | ១.៣៨៥ | ១.៣៨៥ | ៥.៥៦៥ |

| ២០១៧ | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
|---|---|---|---|---|
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ២១.៨០៨ | ៤៦.៤៩១ | ៦៨.២៩៩ | ២៧៥.៧២៣ |
| ការទិញបន្ថែម | - | ២.១០៥ | ២.១០៥ | ៨.៥១៥ |
| ការលុបចោល | - | (១.០៦៩) | (១.០៦៩) | (៤.៣២៤) |
| ការផ្ទេរ | (១៤.១២៩) | - | (១៤.១២៩) | (៥៧.១៥២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ១០៥ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ៧.៦៧៩ | ៤៧.៥២៧ | ៥៥.២០៦ | ២២២.៨៦៧ |
| ដក: **រំលស់បង្គរ** | | | | |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ២១.០៥៤ | ៤៥.៣៣៨ | ៦៦.៣៩២ | ២៦៨.០២៥ |
| រំលស់ក្នុងការិយបរិច្ឆេទ | ៣៨៤ | ៦៨៣ | ១.០៦៧ | ៤.៣១៦ |
| ការលុបចោល | - | (១.០៦៩) | (១.០៦៩) | (៤.៣២៤) |
| ការផ្ទេរ | (១៤.១២៩) | - | (១៤.១២៩) | (៥៧.១៥២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ១១៣ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ៧.៣០៩ | ៤៤.៩៥២ | ៥២.២៦១ | ២១០.៩៧៨ |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ៣៧០ | ២.៥៧៥ | ២.៩៤៥ | ១១.៨៨៩ |

# ១០. ពន្ធលើប្រាក់ចំណេញ

## (ក) បំណុលពន្ធលើប្រាក់ចំណេញ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| នាថ្ងៃទី០១ ខែមករា | ១៨.២៥៣ | ៧៣.៦៨៧ | ៦.៩៩៤ | ២៨.២៣៥ |
| ចំណាយពន្ធលើប្រាក់ចំណេញក្នុងគ្រា | ២.១២៥ | ៨.៥៩៦ | ២០.៩៥៨ | ៨៤.៧៧៥ |
| ពន្ធលើប្រាក់ចំណេញក្នុងគ្រាបានបង់ | (២០.២៦៧) | (៨១.៩៨០) | (៩.៦៩៩) | (៣៩.២៣២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១៩៣ | - | (៩១) |
| នាថ្ងៃទី៣១ ខែធ្នូ | ១១១ | ៤៩៦ | ១៨.២៥៣ | ៧៣.៦៨៧ |

## (ខ) ចំណាយពន្ធលើប្រាក់ចំណេញ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ពន្ធលើប្រាក់ចំណេញក្នុងគ្រា | ២.១២៥ | ៨.៥៩៦ | ២០.៩៥៨ | ៨៤.៧៧៥ |
| ពន្ធពន្យារ | (៨.៤៦៥) | (៣៤.២៤១) | (៥.៣៨២) | (២១.៧៧០) |
| | (៦.៣៤០) | (២៥.៦៤៥) | ១៥.៥៧៦ | ៦៣.០០៥ |

ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធលើប្រាក់ចំណេញ និងចំណេញតាមគណនេយ្យ ៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ប្រាក់ (ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | (៤៦.៥៥៧) | (១៨៨.៣២៣) | ៧៨.៤១៨ | ៣១៧.២០១ |
| ពន្ធលើប្រាក់ចំណេញផ្អែកតាមអត្រាពន្ធជាផ្លូវការ ២០% | (៩.៣១១) | (៣៧.៦៦៣) | ១៥.៦៨៤ | ៦៣.៤៤២ |
| ផលប៉ះពាល់លើ៖ | | | | |
| ចំណាយមិនអាចកាត់កងបាន តាមច្បាប់ពន្ធ | (៤.៤៧៨) | (១៨.១១៤) | (១០៨) | (៤៣៧) |
| ចំណាយមិនបានកត់ត្រា | ៥.៣២៤ | ២១.៥៣៦ | - | - |
| ពន្ធអប្បបរមា | ២.១២៥ | ៨.៥៩៦ | - | - |
| | (៦.៣៤០) | (២៥.៦៤៥) | ១៥.៥៧៦ | ៦៣.០០៥ |

ការគណនាប្រាក់ចំណូលជាប់ពន្ធ គឺស្ថិតនៅក្រោមការពិនិត្យ និងការវាយតម្លៃរបស់អាជ្ញាធរពន្ធដារ ។

## (គ) ពន្ធពន្យារជាទ្រព្យសកម្ម

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ពន្ធពន្យារជាទ្រព្យសកម្ម-សុទ្ធ | ២៣.៩៦៣ | ៩៦.២៨៣ | ១៥.៤៩៨ | ៦២.៥៦៦ |

បម្រែបម្រួលក្នុងពន្ធពន្យារទ្រព្យសកម្មសុទ្ធដែលមានក្នុងឆ្នាំនេះមានដូចខាងក្រោម ៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| នាថ្ងៃទី០១ ខែមករា | ១៥.៩៩៨ | ៦២.៥៦៦ | ១០.១១៦ | ៤០.៨៣៨ |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | ៨.៤៦៥ | ៣៤.២៤១ | ៥.៣៨២ | ២១.៧៧០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៥២៤) | - | (៤២) |
| នាថ្ងៃទី៣១ ខែធ្នូ | ២៣.៩៦៣ | ៩៦.២៨៣ | ១៥.៩៩៨ | ៦២.៥៦៦ |

ពន្ធពន្យារជាទ្រព្យសកម្មដែលត្រូវបានកំណត់ដោយ ៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| រំលស់លើទ្រព្យ និងបរិក្ខារ | ៣១៩ | ១.២៩០ | ៣៨៨ | ១.៥៧០ |
| សំវិធានធនលើប្រាក់រង្វាន់ | ៣៣០ | ១.៣៣៥ | ៨ | ៣២ |
| សំវិធានធនលើអត្ថប្រយោជន៍ | | | | |
| ពេលចូលនិវត្ត | ៧.៥៦៥ | ៣០.៦០១ | ៤.៩៨៦ | ២០.១៦៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ២៥១ | ១.០១៥ | - | - |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ៨.៤៦៥ | ៣៤.២៤១ | ៥.៣៨២ | ២១.៧៧០ |

## ១០. ប្រាក់បញ្ញើមានកាលកំណត់

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.៩១០.០០០ | ៧.៦៧៤.៣៨០ | ១.៨៩០.០០០ | ៧.៦២៩.៩៣០ |
| ការប្រាក់ត្រូវទទួល | ២៥.០១៥ | ១០០.៥១០ | ៣៤.៤៣៩ | ១៣៩.០៣០ |
| | ១.៩៣៥.០១៥ | ៧.៧៧៤.៨៩០ | ១.៩២៤.៤៣៩ | ៧.៧៦៨.៩៦០ |

ក្រុមហ៊ុនបានដាក់ប្រាក់បញ្ញើមានកាលកំណត់នៅក្រុមហ៊ុនមេ ក្នុងរយៈពេលមួយឆ្នាំ ។ ប្រាក់បញ្ញើនេះមានអត្រាការប្រាក់ ៤.៧៥%-៥.៥០% ក្នុង ១ ឆ្នាំ (២០១៧ ៖ ៤.៧៥%) ។

## ១២. ទ្រព្យសកម្មផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| កម្រៃប្រចាំឆ្នាំបង់មុនឲ្យផ្សារមូលបត្រកម្ពុជា | ១៦.៩៣៦ | ៦៨.០៤៩ | ១៦.៤២៨ | ៦៦.៣២០ |
| ទឹកប្រាក់ត្រូវទទួលផ្សេងៗ | ១៣.៨០៥ | ៥៥.៤៦៨ | ១៧.៥៨១ | ៧០.៩៧៤ |
| ប្រាក់បញ្ញើផ្សេងៗ | ៩៩០ | ៣.៩៧៨ | ៩៩០ | ៣.៩៩៧ |
| ចំណាយបង់មុនផ្សេងៗ | ៤.០៥០ | ១៦.២៧៣ | ២៣៥ | ៩៤៩ |
| | ៣៥.៧៨១ | ១៤៣.៧៦៨ | ៣៥.២៣៤ | ១៤២.២៤០ |

## ១៣. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| សាច់ប្រាក់នៅធនាគារ-គណនីសន្សំ | ១២.៣៣៨ | ៤៩.៥៧៤ | ៦៩.៤៧៩ | ២៨០.៤៨៧ |

គណនីសន្សំមានអត្រាការប្រាក់ 0.៥% ក្នុងមួយឆ្នាំ (២០១៧ ៖ 0.៥%)។

ក្រុមហ៊ុនរក្សាគណនីធនាគារមួយឈ្មោះថា "គណនីសាច់ប្រាក់អតិថិជន" នៅធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ទទួលសាច់ប្រាក់របស់អតិថិជន ដែលមានបំណងធ្វើការជួញដូរក្នុងផ្សារមូលបត្រកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយគណនីនេះ មិនត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទេ ដោយយោងទៅតាម ហេតុផលថា គណនីនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រាប់តែទទួលសាច់ប្រាក់ពីអតិថិជនតែប៉ុណ្ណោះ ហើយវាមិនមែនជាកម្មសិទ្ធិរបស់ក្រុមហ៊ុនទេ ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ សមតុល្យគណនីសាច់ប្រាក់អតិថិជិន មានចំនួន ១.៨៩៥.០០៥.៥២១ រៀល ប្រមាណជា ៤៧១.៦២៩ ដុល្លារអាមេរិក (២០១៧៖ ១.០១៧.៩៣៩.៦៣៤ រៀល ប្រមាណជា ២៥២.១៥២ ដុល្លារអាមេរិក) ។

## ១៤. ដើមទុន

ក្រុមហ៊ុនបានចុះបញ្ជីដើមទុនរបស់ខ្លួនចំនួន ៨.២៤០ លានរៀល (ស្មើនឹង២.០១០.០០០ ដុល្លារអាមេរិក) ដោយបានបែងចែកជា ២.០៦០.០០០ ភាគហ៊ុន ដែលមានតម្លៃចារឹក ៤.០០០ រៀល (ស្មើនឹង ១ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន (២០១៧ ៖ ២.០១០.០០០ដុល្លារអាមេរិកតម្លៃចារឹក ១ ដុល្លារអាមេរិក ក្នុង ១ ភាគហ៊ុន) ។ ទឹកប្រាក់ចំនួន២.០១០.០០០ ដុល្លារអាមេរិក ត្រូវបានបង់ទាំងស្រុងដោយក្រុមហ៊ុនមេ ។

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ដើមទុន | ២.០១០.០០០ | ៨.០៤០.០០០ | ២.០១០.០០០ | ៨.០៤០.០០០ |

មិនមានការផ្លាស់ប្តូរនៅក្នុងភាគទុនិក និងរចនាសម្ព័ន្ធភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងឆ្នាំនេះទេឡើយ ។

## ១៥. ភាគពួកិច្ចអត្ថប្រយោជន៍បុគ្គលិក

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានកំណត់ដូចខាងក្រោម ៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| អត្ថប្រយោជន៍ពេលចូលនិវត្ត (ក) | ៤៣.៥៧៥ | ១៧៥.០៨៤ | ២១.២១៣ | ៨៥.៦៣៧ |
| សំណងអតីតភាពការងារ (ខ) | ១៥.៤៦៤ | ៦២.១៣៥ | - | - |
| | ៥៩.០៣៩ | ២៣៧.២១៩ | ២១.២១៣ | ៨៥.៦៣៧ |

### (ក) អត្ថប្រយោជន៍ពេលចូលនិវត្ត

បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងឆ្នាំមានដូចខាងក្រោម ៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| នាថ្ងៃទី០១ ខែមករា | ២១.២១៣ | ៨៥.៦៣៧ | ១៦.២៤០ | ៦៥.៥៦១ |
| ចំណាយការប្រាក់ | ៦៩០ | ២.៧៩១ | ១.០៣៩ | ៤.២០៣ |
| ចំណាយសេវាក្នុងឆ្នាំ | ១.៧៨៥ | ៧.២២០ | ៣.០១៧ | ១២.២០៤ |
| ខាតពីការវាស់វែងបណ្តាលមកពីការផ្លាស់ប្តូរការសន្មតឡើងវិញ | ១៩.៨៨៧ | ៨០.៤៤៣ | ៩១៧ | ៣.៧០៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១.០០៧) | - | (៤០) |
| នាថ្ងៃទី៣១ ខែធ្នូ | ៤៣.៥៧៥ | ១៧៥.០៨៤ | ២១.២១៣ | ៨៥.៦៣៧ |

ចំនួនទឹកប្រាក់ដែលបានកត់ត្រាក្នុងរបាយការណ៍ចំណេញ-ខាតមានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ចំណាយការប្រាក់ | ៦៩០ | ២.៧៩១ | ១.០៣៩ | ៤.២០៣ |
| ចំណាយសេវាក្នុងឆ្នាំ | ១.៧៨៥ | ៧.២២០ | ៣.០១៧ | ១២.២០៤ |
| | ២.៤៧៥ | ១០.០១១ | ៤.០៥៦ | ១៦.៤០៧ |

ចំនួនទឹកប្រាក់ដែលបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលលម្អិត មានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ខាតពីការវាស់វែងបណ្តាលមកពីការផ្លាស់ប្តូរការសន្មតហានិភ័យ ឡើងវិញ | ១៩.៨៨៧ | ៨០.៤៨៣ | ៩១៧ | ៣.៧០៩ |

ការសន្មតសំខាន់ៗដែលបានប្រើប្រាស់ដើម្បីកំណត់ចំណាយកាតព្វកិច្ចប៉ាន់ស្មាន មានដូចខាងក្រោម៖

| | ២០១៨ | ២០១៧ |
|---|---|---|
| អត្រាកំណើនប្រាក់បៀវត្ស | ៣,៨៧% | ៤,២០% |
| អត្រាអតិផរណា | ១,២០% | ១,២០% |
| អត្រាអប្បហារ | ៧,០០% | ៦,៥០% |
| អត្រាមរណៈ (*) និងអត្រាបម្រែបម្រួលបុគ្គលិក (**) | - | - |

(*) តារាងអត្រាមរណៈមានដូចខាងក្រោម៖

| អាយុ | អត្រាមរណៈ(%ក្នុងមួយឆ្នាំ) | | | |
|---|---|---|---|---|
| | ២០១៨ | | ២០១៧ | |
| | ស្ត្រី | បុរស | ស្ត្រី | បុរស |
| ១៨-២៩ | ០-០,២២ | ០-០,៤០ | ០-០,៣៩ | ០-១,១៧ |
| ៣០-៣៩ | - | ០-០,២៦ | - | ០–០,៤០ |
| ៤០-៤៩ | - | - | - | - |
| ៥០-៥៩ | - | - | - | - |
| ៦០ | - | - | - | - |

(**) តារាងអត្រាបម្រែបម្រួលបុគ្គលិកអត្រាលាឈប់របស់បុគ្គលិក មានដូចខាងក្រោម៖

| អាយុ | អត្រាបម្រែបម្រួលបុគ្គលិក (%ក្នុងមួយឆ្នាំ) | | | |
|---|---|---|---|---|
| | ២០១៨ | | ២០១៧ | |
| | ស្ត្រី | បុរស | ស្ត្រី | បុរស |
| ១៨ - ២៩ | ០ - ៤,៣៤ | ២,៥០ - ៤,៥៣ | ១,៥៥ - ៤,៨៤ | ១,៣៦ – ៤,៥៤ |
| ៣០ - ៣៩ | ១,៧៣ - ៤,៦៣ | ២,៩៨ - ៥,២១ | ០ – ៣,៩២ | ២,៩២ - ៦,៦២ |
| ៤០ - ៤៩ | ០ - ១៤,០៧ | ០ - ៣,៨២ | - | ០ - ៥,៩០ |
| ៥០ - ៥៩ | ០ - ១៣,៣៣ | ០ - ១១,៨៣ | - | ០ – ៧,៨១ |
| ៦០ | - | - | - | - |

## (ខ) សំណាងអតីតភាពការងារ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| នាថ្ងៃទី០១ ខែមករា | - | - | - | - |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | ១៥.៤៦៤ | ៦២.៥៥២ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៤១៧) | - | - |
| នាថ្ងៃទី៣១ ខែធ្នូ | ១៥.៤៦៤ | ៦២.១៣៥ | - | - |

## ១៦. បង្គរ និងគណនីត្រូវទូទាត់ផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| បង្គរច្បាប់ឈប់សម្រាកប្រចាំឆ្នាំ | ៤៣.៩៩៣ | ១៧៦.៧៦៣ | ៣៧.៣៧១ | ១៥០.៨៦៧ |
| បង្គរប្រាក់រង្វាន់ | - | - | ៤.៩៧៦ | ២០.០៨៨ |
| ពន្ធត្រូវបង់ | ១.៧២៩ | ៦.៩៤៧ | ១.៤៨៦ | ៥.៨៣៨ |
| បង្គរផ្សេងៗ | ១៧.១៦៤ | ៦៨.៩៦៥ | ៥.៩៨៦ | ២៤.១៦៥ |
| | ៦២.៨៨៦ | ២៥២.៦៧៥ | ៤៩.៧៧៩ | ២០០.៩៥៨ |

## ១៧. ប្រតិបត្តិការសម្ព័ន្ធញាតិ

| សម្ព័ន្ធញាតិ | ទំនាក់ទំនង |
|---|---|
| ធនាគារ អេស៊ីលីដា ភីអិលស៊ី | ក្រុមហ៊ុនមេ |
| ក្រុមហ៊ុនពាក់ព័ន្ធ | ក្រុមហ៊ុននានាដែលស្ថិតនៅក្រោមក្រុមហ៊ុនមេតែមួយ |
| គណៈគ្រប់គ្រងសំខាន់ៗ | បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ គឺជាបុគ្គលទាំងឡាយណាដែលមានសិទ្ធិ អំណាច និងការទទួលខុសត្រូវក្នុងការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យសកម្មភាពនានារបស់ក្រុមហ៊ុន ។ បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុន រួមមាន អភិបាលទាំងអស់ និងសមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន ។ |

ប្រតិបត្តិការខាងក្រោមនេះ ត្រូវបានធ្វើឡើងជាមួយសម្ព័ន្ធញាតិ ។

## (ក) ចំណូលការប្រាក់ពីក្រុមហ៊ុនមេ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ចំណូលការប្រាក់ | ៩២.២២០ | ៣៧៣.០៣០ | ១១៥.៤០៩ | ៤៦៦.៤២៩ |

## (ខ) កម្រៃ និងចំណាយជូនក្រុមហ៊ុនមេ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| ចំណាយទឹក-ភ្លើង | ៤.៣២០ | ១៧.៤៧៤ | ១៦.៨៦០ | ៦៨.១៩៩ |
| សេវាធនាគារ | ៣២៧ | ១.៣១៤ | ៣៥១ | ១.៤២០ |
| | ៤.៦៤៧ | ១៨.៧៨៨ | ១៧.២១១ | ៦៩.៦១៩ |

## (គ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី | ១២៥.៩៥៦ | ៥០៦.០៩១ | ៩២.១៩៥ | ៣៧១.៩៨៩ |
| អត្ថប្រយោជន៍បុគ្គលិករយៈពេលវែង | ៥៣.៣៩៤ | ២១៤.៥៣៧ | ២២.៧១៣ | ៩១.៦៩២ |
| អត្ថប្រយោជន៍ក្រោយពេលបញ្ចប់ការងារ | ២៧.៩៨៧ | ១១២.៤៥២ | ១២.៩៩៥ | ៥០.៦៤៤ |
| | ២០៧.៣៣៧ | ៨៣៣.០៨០ | ១២៧.៩០៣ | ៥១៤.៣២៥ |

## (ឃ) សមតុល្យចុងឆ្នាំកើតឡើងពីប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| គណនីសន្សំ (កំណត់សម្គាល់ ១៣) | ១២.៣៣៨ | ៤៩.៥៧៤ | ៦៩.៤៧៩ | ២៨០.៤៨៧ |
| ប្រាក់បញ្ញើមានកាលកំណត់ (កំណត់សម្គាល់ ១១) | ១.៩១០.០០០ | ៧.៦៧៤.៣៨០ | ១.៨៩០.០០០ | ៧.៦២៩.៩៣០ |
| ការប្រាក់ត្រូវទទួល (កំណត់សម្គាល់ ១១) | ២៥.០១៥ | ១០០.៥១០ | ៣៤.៤៣៩ | ១៣៩.០៣០ |
| | ១.៩៤៧.៣៥៣ | ៧.៨២៤.៤៦៤ | ១.៩៩៣.៩១៨ | ៨.០៤៩.៤៤៧ |

## ១៨. ឧបករណ៍ហិរញ្ញវត្ថុ - តម្លៃសមស្រប និងការគ្រប់គ្រងហានិភ័យ

### (ក) ការចាត់ថ្នាក់គណនេយ្យ និងតម្លៃសមស្រប

ក្រុមហ៊ុនមិនធ្វើការបង្ហាញអំពីព័ត៌មានតម្លៃសមស្របសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ព្រោះតម្លៃយោងគឺសមស្របប្រហាក់ប្រហែលទៅនឹងតម្លៃសមស្រប។

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

(i) សេចក្ដីសង្ខេប

ក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យដូចខាងក្រោម ដែលកើតពីឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន ៖

- ហានិភ័យឥណទាន
- ហានិភ័យសាច់ប្រាក់ងាយស្រួល និង
- ហានិភ័យទីផ្សារ

កំណត់សម្គាល់នេះ ត្រូវបានបង្ហាញព័ត៌មានអំពីហានីភ័យក្រុមក្នុងប្រភេទនៃហានីភ័យនីមួយៗ ដូចខាងលើ គោលបំណង គោលនយោបាយ និងដំណើរការរបស់ក្រុមហ៊ុនគឺដើម្បីវាស់វែង និងគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងដើមទុនរបស់ក្រុមហ៊ុន ។

### (ii) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ហិរញ្ញវត្ថុប្រសិនបើអតិថិជន ឬដៃគូពាណិជ្ជកម្ម មិនបំពេញតាមកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចសន្យា ។

អ្នកគ្រប់គ្រងមានគោលនយោបាយឥណទាន ហើយការប្រឈមរបស់ក្រុមហ៊ុនទៅនឹងហានិភ័យឥណទាន ត្រូវបានត្រួតពិនិត្យដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ។ ការវាយតម្លៃឥណទាន ត្រូវបានធ្វើឡើង ចំពោះគ្រប់អតិថិជនទាំងអស់ដែលមានឥណទានលើចំនួនកំណត់ ។ ក្រុមហ៊ុនមិនតម្រូវឲ្យមានទ្រព្យបញ្ចាំសម្រាប់ទ្រព្យសកម្មទេ ។

គ្មានការផ្តោតសំខាន់ទៅលើហានិភ័យឥណទានទេ ។ ការប្រឈមអតិបរមាទៅនឹងហានិភ័យឥណទាន គឺបានបង្ហាញតាមតម្លៃយោងនៃទ្រព្យសកម្មនីមួយៗក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

### (iii) ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែលក្រុមហ៊ុនមិនអាចបំពេញកាតព្វកិច្ចទាក់ទងនឹងបំណុលហិរញ្ញវត្ថុ ដែលត្រូវទូទាត់ដោយប្រើសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុ ។ គោលដៅរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រង ហានិភ័យសាច់ប្រាក់ងាយស្រួល គឺធានាការរក្សាកម្រិតទ្រព្យសកម្មងាយស្រួលឲ្យបាន គ្រប់គ្រាន់ទាំងក្នុងពេល ធម្មតា ឬមានបញ្ហា ដោយមិនមានការកើតឡើងនូវការខាតបង់ដែលមិនអាចទទួលយកបាន ឬហានិភ័យដែលប៉ះពាល់ដល់កិត្តិនាមរបស់ក្រុមហ៊ុន ។

ក្រុមហ៊ុនត្រួតពិនិត្យហានិភ័យសាច់ប្រាក់ងាយស្រួល និងរក្សាកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលឲ្យបានគ្រប់គ្រាន់ សម្រាប់ទ្រទ្រង់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន និងដើម្បីបន្ថយផលប៉ះពាល់នៃការប្រែប្រួលនូវលំហូរសាច់ប្រាក់ ។

## ការប្រឈមនូវហានិភ័យសាច់ប្រាក់ងាយស្រួល

តារាងខាងក្រោមនេះ គឺជាកាលវសាន្តនៃអនិស្សន្ទបំណុលហិរញ្ញវត្ថុដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍ ។ ចំនួននេះ គឺចំនួនដុល និងមិនអប្បហារ និងរួមមានការបង់ការប្រាក់ប៉ាន់ស្មាន និងមិនបញ្ចូលកិច្ចព្រមព្រៀងកាត់កង ។

| ២០១៨ | តម្លៃយោង ដុល្លារអាមេរិក | លំហូរទឹកប្រាក់ដុល តាមកិច្ចសន្យា ដុល្លារអាមេរិក | ៦ ខែ ឬតិចជាង ដុល្លារអាមេរិក | ៦-១២ ខែ ដុល្លារអាមេរិក | លើសពី ១ ឆ្នាំ ដុល្លារអាមេរិក |
|---|---|---|---|---|---|
| គណនីត្រូវទូទាត់ផ្សេងៗ | ១៧.១៦៤ | ១៧.១៦៤ | ១២.១៨៦ | ៤.៩៧៨ | - |
| **ស្មើនឹងពាន់រៀល** (កំណត់សម្គាល់ ៦) | | | | | |
| គណនីត្រូវទូទាត់ផ្សេងៗ | ៦៨.៩៦៥ | ៦៨.៩៦៥ | ៤៨.៩៦៣ | ២០.០០២ | - |
| **២០១៧** | | | | | |
| គណនីត្រូវទូទាត់ផ្សេងៗ | ៥.៧៥២ | ៥.៧៥២ | ៥.៧៥២ | - | - |
| **ស្មើនឹងពាន់រៀល** (កំណត់សម្គាល់ ៦) | | | | | |
| គណនីត្រូវទូទាត់ផ្សេងៗ | ២៣.២២១ | ២៣.២២១ | ២៣.២២១ | - | - |

(iv) ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យនៃការប្រែប្រួលតម្លៃទីផ្សារដូចជា អត្រាប្តូរប្រាក់ អត្រាការប្រាក់ដែលប៉ះពាល់ដល់ចំណូល ឬតម្លៃនៃការកាន់កាប់នូវឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។ គោលបំណងនៃការគ្រប់គ្រងហានិភ័យ ទីផ្សារគឺដើម្បីគ្រប់គ្រង និងត្រួតពិនិត្យនូវការផ្ទុះឡើងហានិភ័យទីផ្សារ ក្នុងកម្រិតមួយទទួលយកបានខណៈពេល ដែលផ្តល់មកវិញនូវចំណូលជាអតិបរមា ។

### ហានិភ័យរូបិយប័ណ្ណបរទេស

ក្រុមហ៊ុនមិនមានហានិភ័យរូបិយប័ណ្ណបរទេសជាសារវន្តនោះទេ ដោយសារប្រតិបត្តិការភាគច្រើនរបស់ក្រុមហ៊ុន ត្រូវបានធ្វើឡើងប្រាក់ជាដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ។

### ហានិភ័យអត្រាការប្រាក់

ការប្រឈមទៅនឹងហានិភ័យការប្រាក់របស់ក្រុមហ៊ុន ពាក់ព័ន្ធទៅនឹងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលមានការប្រាក់ ។

*ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលមានការប្រាក់*

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការប្រាក់ រួមមានប្រាក់បញ្ញើនៅធនាគារ ។ អត្រាការប្រាក់ និងកាលកំណត់នៃសមតុល្យធនាគារ ត្រូវបានបង្ហាញនៅកំណត់សម្គាល់ ១១ ។ គ្មានបំណុលហិរញ្ញវត្ថុដែលមានការប្រាក់នៅកាលបរិច្ឆេទរាយការណ៍ទេ ។

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| **ឧបករណ៍អត្រាថេរ** | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | |
| (រួមបញ្ចូលការប្រាក់) | ១.៩៣៥.០១៥ | ៧.៧៧៤.៨៩០ | ១.៩២៤.៤៣៩ | ៧.៧៦៨.៩៦០ |

*ការវិភាគរំញោចលើលំហូរសាច់ប្រាក់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់អថេរ*

ក្រុមហ៊ុនពុំមានឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់អថេរជាសារវន្តនោះទេ ។ ដូច្នេះការវិភាគរំញោចលើ លំហូរសាច់ប្រាក់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់អថេរ មិនត្រូវបានបង្ហាញឡើយ ។

គោលបំណងរបស់ក្រុមហ៊ុននៅពេលគ្រប់គ្រងដើមទុន គឺដើម្បីការពារសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តជាការព្រួយបារម្ភក្នុងគោលបំណងដើម្បីផ្តល់ត្រឡប់មកវិញ សម្រាប់ភាគទុនិក និងអត្ថប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធដទៃទៀត និងដើម្បីរក្សារចនាសម្ព័ន្ធដើមទុនល្អប្រសើរ ដើម្បីកាត់បន្ថយដើមទុន ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ក្រុមហ៊ុនមានដើមទុនចំនួន ២.០១០.០០០ ដុល្លារអាមេរិក ហើយមិនមានបំណុលភាគីម្ខាងទៀតទេ ហើយបានបំពេញតាមលក្ខខណ្ឌដើមទុនអប្បបរមាចំនួន ១.៥០០.០០០ ដុល្លារអាមេរិក ។

លើសពីនេះទៅទៀតក្រោមបទបញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនត្រូវរក្សាសមាមាត្រដើមទុន ១៥០%។ ដើមទុនសុទ្ធរបស់ក្រុមហ៊ុន និងសមាមាត្រដើមទុនសុទ្ធ នាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម ៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៦) |
| **ដើមទុនសុទ្ធ** | | | | |
| ទ្រព្យសកម្មចរន្តសរុប | ២.១៧១.២១៨ | ៨.៧២៣.៩៥៤ | ២.២០៧.១៨៨ | ៨.៩១០.៩១៧ |
| បំណុលខាងក្រៅសរុប | (១២២.០៣៦) | (៤៩០.៣៤០) | (៨៩.២៤៥) | (៣៦០.២៨២) |
| | ២.០៤៩.១៨២ | ៨.២៣៣.៦១៤ | ២.១១៧.៩៤៣ | ៨.៥៥០.១៣៥ |
| កម្រិតដើមទុនដែលបានកំណត់ (ខ្ពស់ជាង ក និង ខ) | | | | |
| ៥% នៃមូលធនភាគទុនិក (ក) | ១០៧.៥៣៨ | ៤៣២.០៨៩ | ១១០.៥៤៤ | ៤៤៦.២៦៤ |
| ១០% នៃបំណុលខាងក្រៅសរុប (ខ) | ១២.២០៤ | ៤៩.០៣៤ | ៨.៩២៥ | ៣៦.០២៨ |
| **កម្រិតដើមទុនដែលបានកំណត់** | ១០៧.៥៣៨ | ៤៣២.០៨៩ | ១១០.៥៤៤ | ៤៤៦.២៦៤ |
| **សមាមាត្រដើមទុនសុទ្ធ** | ១៩០៦% | ១៩០៦% | ១៩១៦% | ១៩១៦% |

## ១៩. យថាភាពលើពន្ធ

ពន្ធត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានអង្កេតដោយក្រុមអាជ្ញាធរ ដែលផ្តល់សិទ្ធិដោយច្បាប់ក្នុងការ ដាក់ពិន័យ ដាក់ទណ្ឌកម្ម និងការគិតការប្រាក់ ។ ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការច្រើនប្រភេទ ប្រឈមនឹងបំណាកស្រាយផ្សេងៗ ។

បញ្ហាទាំងនេះ អាចបង្កើតឲ្យមានហានិភ័យពន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈធំជាងនៅប្រទេសដទៃទៀត ។ អ្នកគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ ដោយផ្អែកទៅលើការបកស្រាយនៃនីតិកម្មពន្ធ ។ ក៏ប៉ុន្តែ អាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានបំណាកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ ។

ការិយាល័យកណ្តាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៧២៣ ៣៨៨ / ៩៩៩ ៩៧៧
info@acledasecurities.com.kh | www.acledasecurities.com.kh